# ការគិតឡើងវិញ **អំពីស្ត្រីមូស្លីម**
# **&ស្បៃគ្របមុខ**

## ប្រវត្តិសាស្ត្រប្រកបដោយភាពប្រឈម និងគំរូនៃភាពទំនើប




IIIT Books-In-Brief Series

# ការគិតឡើងវិញ

# អំពីស្ត្រី

# មូស្លីម និង

# ស្បៃគ្របមុខ

ប្រវត្តិសាស្ត្រប្រកបដោយភាពប្រឈម
និងគំរូនៃភាពទំនើប

Katherine Bullock

@វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ ឆ្នាំ២០២៥

វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ(IIIT)
P.O. BOx 669
Herndon, VA 20172, USA
www.iiit.org

IIIT London Office
P.O. Box 126
Richmond, Surrey
TW9 2UD, UK
www.iiituk.com

សៀវភៅនេះស្ថិតក្នុងការរក្សាកម្មសិទ្ធិ។ កម្មវត្ថុនៃការលើកលែង និងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងជាសមូហភាពដែលពាក់ព័ន្ធមិនអាចផលិតឡើងវិញនូវផ្នែកណាមួយនៃសៀវភៅនេះ  អាចធ្វើទៅបាននោះឡើយ បើសិនជាមិនមានការសរសេរលាយលក្ខណ៍អក្សរនៃការអនុញ្ញាតពីអ្នកបោះពុម្ពផ្សាយ។

ទស្សនៈ និងគំនិតដែលបានបង្ហាញក្នុងសៀវភៅនេះគឺជាគំនិតរបស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈ របស់អ្នកបោះពុម្ពឡើយ។

ISBN: 979-8-89193-400-9 Paperback
ISBN: 979-8-89193-401-6 ebook

ក្រុមអ្នករចនាឌីសាញ
Dr. Anas S. al-Shaikh-Ali
Shiraz Khan

អ្នករចនាគម្របសៀវភៅដោយ Shiraz Khan

## ប្រភេទសៀវភៅសង្ខេបរបស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ(IIIT)

សៀវភៅ IIIT Books-In-Brief Series គឺជាការប្រមូលផ្តុំដ៏មានតម្លៃនៃសៀវភៅ ដែលបានបោះពុម្ពផ្សាយសំខាន់ៗ របស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តជាតិ(IIIT) ដែលបានសរសេរ រៀបចំឡើងជាទម្រង់សង្ខេបខ្លី ខ្លឹម ដើម្បីផ្តល់ឱ្យមិត្តអ្នកអាន នូវការយល់ដឹងអំពីស្នូលនៃខ្លឹមសារសំខាន់ៗ នៃស្នាដៃសៀវភៅច្បាប់ដើមតែម្តង។ រៀបចំឡើងក្នុងទម្រង់ខ្លី ងាយស្រួលអានសន្សំសំចៃពេលវេលា សេចក្តី សង្ខេបនៃបណ្តាសៀវភៅទាំងនេះបានផ្តល់នូវភាពខ្លឹមនៃការបង្រួមខ្លឹមសាឲ្យកាន់តែខ្លី និងសរសេរ ដោយប្រុងប្រយ័ត្នបំផុតពីសៀវភៅដែលបានបោះពុម្ពដើមដែលមានពិពណ៌នាច្រើនជាងនេះ ដែលយើងខ្ញុំសង្ឃឹមថាមិត្តអ្នកអាននឹងស្វែងយល់បន្ថែមពីបណ្តាសៀវភៅដើមពេញទំព័រ ដែលមិនទាន់បានសង្ខេបជាបន្ត។

សុន្ទរកថារបស់Dr. Katherine Bullock ស្តីពីការគិតឡើងវិញអំពីស្ត្រីមូស្លីម និងស្បៃគ្របមុខ ត្រូវបានបោះពុម្ពជាលើកដំបូងទី១ដោយវិទ្យាស្ថាន IIIT នៅក្នុងឆ្នាំ២០០២ និងការបោះពុម្ពលើកទី២នៅក្នុងឆ្នាំ២០០៧។ វាគឺជាការរិះគន់ដ៏ខ្លាំងក្លា និងគោលគំនិតលោកខាងលិចដ៏ពេញនិយមដែលលើកឡើងថាស្បៃគ្របមុខជានិមិត្តរូបនៃការជិះជាន់សម្រាប់ស្ត្រីមូស្លីម។ និយាយអំពីបញ្ហាសំខាន់ៗជាច្រើនក្នុងសង្គម-នយោបាយ ដែលជាបញ្ហាសកលនេះត្រូវបានលើកឡើង អ្នកនិពន្ធបានពិនិត្យមើលការកែខៃ នៅក្នុងប្រវត្តិសាស្ត្ររបស់លោកខាងលិចជាមួយនឹងពាក្យស្បៃគ្របមុខ (រួមនឹងទិដ្ឋភាពនៃអាណានិគមនិយម និងហ្វាតទីហ្សឹម) វាយតម្លៃលើសុន្ទរកថានិយមស្ត្រី និងផ្តល់នូវទ្រឹស្តីផ្សេងជំនួសឲ្យស្បៃគ្របមុខរបស់ស្ត្រី ពោលគឺឲ្យតម្លៃលើសេរីភាពខ្លាំងជាងសេចក្តីថ្លៃថ្នូររបស់ស្ត្រី។ លក្ខណៈសំខាន់នៃស្នាដៃនេះគឺសំឡេងដែលអ្នកនិពន្ធមានផ្តល់អោយនូវទិដ្ឋភាព ទស្សនៈ បទពិសោធន៍ និងទិដ្ឋភាពគំរូ នៃស្ត្រីមូស្លីមដែលបានសម្ភាសន៍នៅប្រទេសកាណាដានៅលើប្រធានបទហ៊ីហ្សាប ឬស្បៃគ្របមុខរបស់ស្ត្រីមូស្លីម។

អ្នកនិពន្ធសៀវភៅនេះបានទទួលយកសាសនាអ៊ីស្លាម នៅអំឡុងពេលសិក្សាជាបេក្ខជនថ្នាក់បណ្ឌិត និងអ្វីដែលគួរគួរឱ្យចាប់អារម្មណ៍នោះ វាគឺជាបទពិសោធន៍នៃប្រតិកម្មរបស់មនុស្សចំពោះនាង អំពីការប្រែចិត្តមានជំនឿ ដែលវានាំឱ្យនាងផ្លាស់ប្តូរប្រធានបទដើមនៃនិក្ខេបបទបណ្ឌិត និងជ្រើសរើសជំនួសវិញលើការសិក្សាអំពីហ៊ីហ្សាបស្បៃគ្របមុខរបស់ស្ត្រីមូស្លីមជាប្រធានបទថ្នាក់បណ្ឌិតរបស់នាងវិញ។ តាមរយៈការសិក្សាដោយប្រុងប្រយ័ត្ន និងយ៉ាងល្អិតល្អន់ទៅក្នុងផ្នែកមួយដែលពោរពេញទៅដោយការយល់ខុសនៅក្នុងប្រវត្តិសាស្ត្រ និងវប្បធម៌ អ្នកនិពន្ធបានស្វែងរកបញ្ហាប្រឈមមុខទៅនឹងប្រធានបទ និងមូលដ្ឋានអវិជ្ជមានមួយចំនួនដែលបានមកលប់ច្រើនទៅលើសុន្ទរកថានៅក្នុងបញ្ហាសំខាន់នាពេលបច្ចុប្បន្ននេះ។

ការងាររបស់Dr. Bullock បង្កើតជាសាវតារដ៏សំខាន់មួយលើការសិក្សា ឬការជជែកវែកញែកអំពីបញ្ហានយោបាយដ៏ធំ និងកំពុងរីកសាយនៅលោកខាងលិចអំពីហ៊ីហ្សាប ឬស្បៃគ្របមុខ។

**ការបោះពុម្ពស្នាដៃសៀវភៅសង្ខេបពីប្រកពដើមនៃស្នាដៃរបស់ Katherine Bullock**

*នៃសៀវភៅការគិតឡើងវិញអំពីស្ត្រីមូស្លីមនិងស្បៃគ្របមុខ:*

ប្រវត្តិសាស្ត្រប្រកបដោយភាពប្រឈម និងគំរូនៃភាពទំនើប

Katherine Bullock

ISBN hbk: 978-1-56564-433-5

ISBN pbk: 978-1-56564-432-8

2007

# ការណែនាំ

នៅក្នុងឆ្នាំ១៩៩១ ខ្ញុំបានឃើញរព័ត៌មានមួយ នៅលើកញ្ចក់ទូរទស្សន៍ដែលបង្ហាញអំពីស្ត្រីនៅប្រទេសទួរគីដែលពួកគេកំពុងត្រឡប់ទៅពាក់ហ៊ីយ៉ាបគ្របមុខឡើងវិញ។ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើល និងមានសោកស្តាយចំពោះពួកគេ។ រឿងមិនល្អនោះ ខ្ញុំគិតថាពួកគេកំពុងត្រូវបានលាងខួរក្បាលដោយវប្បធម៌របស់ពួកគេ។ ដូចជាជនជាតិលោកខាងលិចជាច្រើនផងដែរ ខ្ញុំជឿថាសាសនាអ៊ីស្លាមគាបសង្កត់ស្ត្រី និងហ៊ីហ្ជាបស្បៃគ្របមុខគឺជានិមិត្តរូបនៃការជិះជាន់របស់ពួកគេ។ ចូរស្រមៃគិតអំពីការភ្ញាក់ផ្អើលរបស់ខ្ញុំនៅពេលនោះ ៤ឆ្នាំក្រោយមក នៅពេលខ្ញុំបានឃើញរូបពីកញ្ចក់របស់ខ្ញុំផ្ទាល់នៅក្នុងបង្អួចហាង ដែលបានស្លៀកពាក់ដូចស្ត្រីដែលត្រូវគេជិះជាន់នោះ។ ខ្ញុំបានចាប់ផ្តើមដំណើរនូវការកែប្រែស្មារតីបញ្ញាញាណរបស់ខ្ញុំនៅក្នុងអំឡុងពេលខ្ញុំរៀននៅថ្នាក់អនុបណ្ឌិតរបស់ខ្ញុំ៤ឆ្នាំក្រោយមក ខ្ញុំបានកែប្រែចិត្ត មានជំនឿរបស់ខ្ញុំចំពោះសាសនាអ៊ីស្លាម។ ដំណើរនេះរួមមានការផ្លាស់ប្តូរពីការស្អប់ខ្ពើមសាសនាអ៊ីស្លាម ទៅជាការគោរព ទៅជាការចាប់អារម្មណ៍ និងការទទួលយកអ៊ីស្លាម។ ធម្មជាតិជាមនុស្សស្រីបញ្ហានៃ ការពាក់ហ៊ីហ្ជាបគ្របស្បៃមុខគឺជាចំណុចកណ្តាល។

ថ្វីបើខ្ញុំចាប់អារម្មណ៍នឹងមូលដ្ឋានគ្រឹះខាងទ្រឹស្តីនៃសាសនាអ៊ីស្លាមក៏ដោយ ខ្ញុំមានការពិបាកចិត្តយ៉ាងខ្លាំងចំពោះអ្វីដែលខ្ញុំជឿថាជាការអនុវត្តជាការសង្កត់សង្កិនស្ត្រី។ ខ្ញុំមានអារម្មណ៍ថាហ៊ីយ៉ាបស្បៃមុខជាវប្បធម៌ប្រពៃណីដែលស្ត្រីមូស្លីមពិតជាអាចធ្វើការដើម្បីលុបបំបាត់បាន។ ខ្ញុំត្រូវបានគេបង្ហាញវាក្យខណ្ឌនៅក្នុងគម្ពីរអាល់គួរអាន ដែលប្រជាជនមូស្លីមជាច្រើនជឿលើការតម្រូវឲ្យគ្របដណ្តប់លើបុរស និងស្ត្រី និងវាហាក់ដូចជាច្បាស់ណាស់សម្រាប់ខ្ញុំនៅពេលនោះជាការពិត វាក្យខណ្ឌនៃគម្ពីរអាល់គួរអានបានកំណត់ឲ្យគ្របដណ្តប់។ ខ្ញុំបានទៅផ្ទះដោយមានអារម្មណ៍ក្រៀមក្រំ និងសោកស្តាយសម្រាប់ស្ត្រីមូស្លីម។ ប្រសិនបើវាក្យខណ្ឌគម្ពីរអាល់គួរអានច្បាស់ ពួកគេនឹងគ្មានសិទ្ធិទេ៖ ការគ្របដណ្តប់បិទបាំងរាងកាយនឹងត្រូវបានទាមទារ តម្រូវសម្រាប់ស្ត្រីមូស្លីមដែលមានជំនឿ។

ខ្ញុំត្រូវដាក់បញ្ហាទាំងនេះមួយឡែកសិន ដើម្បីសម្រេចចិត្តថាទទួល ឬមិនទទួលយកសាសនាអ៊ីស្លាម។ អ្វីដែលត្រូវបានរាប់នៅក្នុងការវិភាគចុងក្រោយគឺសារជាមូលដ្ឋាននៃសាសនាអ៊ីស្លាម

នោះគឺមានព្រះតែមួយគត់ និងមហាំម៉ាត់ (SAAS) * គឺជាខ្ញុំបម្រើ និងជាអ្នកនាំសារចុងក្រោយរបស់អល់ឡោះ។ បន្ទាប់ពីការសិក្សាជាច្រើនឆ្នាំ ខ្ញុំគ្មានការសង្ស័យអំពីវា... ប្រសិនបើវាមិនមែនជាបញ្ហាសម្រាប់ស្ត្រី និងសាសនាអ៊ីស្លាម។

នៅពេលដែលខ្ញុំបានសម្រេចចិត្តចុងក្រោយរបស់ខ្ញុំដើម្បីផ្លាស់ប្តូរចិត្តមានជំនឿ ពោលជឿលើសាសនាអ៊ីស្លាម។ ឥឡូវនេះ១ឆ្នាំកន្លះចូលថ្នាក់បណ្ឌិតរបស់ខ្ញុំ (ខែកក្កដា ១៩៩៤) ខ្ញុំបានសម្រេចចិត្តថាខ្ញុំចូលចិត្តឬអត់ ខ្ញុំគួរបិទបាំងវា។ វាជាបញ្ញត្តិមួយ និងខ្ញុំនឹងគោរពតាម។ ខ្ញុំបានប្រាប់មនុស្សមួយចំនួន នៅក្នុងផ្នែករបស់ខ្ញុំថា ខ្ញុំបានក្លាយជាអ្នកកាន់សាសនាអ៊ីស្លាមហើយ ពេលក្រោយមកពួកគេបានឃើញខ្ញុំ ខ្ញុំនឹងទទួលហ៊ីយ៉ាប់។ មិនចាំបាច់និយាយទេ មនុស្សពិតជាតក់ស្លុតយ៉ាងខ្លាំង និងនៅពេលនោះដែលពាក្យជាច្រើនពីពួកគេ (ហើយដូចដែលមនុស្សបានឃើញខ្ញុំក្នុងសម្លៀកបំពាក់ថ្មីរបស់ខ្ញុំ) ខ្ញុំបានសង្កេតឃើញថាខ្លួនខ្ញុំទទួលបាននូវការព្យាបាលផ្នែកខាងក្នុងខ្លួនមួយចំនួន។ តើខ្ញុំអាចទទួលយកការគៀបសង្កត់ដោយរបៀបណាជាពិសេសនៅពេលដែលខ្ញុំត្រូវបានគេស្គាល់ថាជាអ្នកនិយមលើស្ត្រីខ្លាំង និងមានការប្តេជ្ញាចិត្ត? តើខ្ញុំអាចទទួលយកអ៊ីស្លាមបានដែរឬទេ? តើខ្ញុំមិនបានឮអ្វីដែលក្រុមហាម៉ាសទើបតែបានធ្វើ? តើខ្ញុំមិនបានឮពីអ្វីដែលបុរសមូស្លីមមួយចំនួនបានធ្វើទៅស្ត្រីទេឬ? ខ្ញុំមិនបានត្រៀមខ្លួនសម្រាប់អរិភាពនេះទេ និងក៏មិនបានត្រៀមខ្លួនសម្រាប់វិធីផ្សេងៗដទៃទៀតដែលខ្ញុំត្រូវបានគេចាត់ទុក ដោយអ្នកផ្សេងដូចជាលេខាធិការការិយាល័យ បុគ្គលិកពេទ្យ ឬមនុស្សចម្លែកប្លែកមុខទូទៅនៅលើរថភ្លើងក្រោមដី។ ខ្ញុំមានអារម្មណ៍ដូចគ្នា ប៉ុន្តែខ្ញុំត្រូវបានគេមើលងាយជាញឹកញាប់បែបនេះ។ ស្ត្រី វាគឺជាបទពិសោធន៍ផ្ទាល់ខ្លួនដំបូងរបស់ខ្ញុំអំពីការមើលងាយ និងការរើសអើងជាតិសាសន៍ និងបានធ្វើឱ្យខ្ញុំពីមុនតាមរបៀបដែលខ្ញុំមិនធ្លាប់យល់ច្បាស់ពីមុនមកនោះ។

មិត្តភក្តិជាស្ត្រីមូស្លីមថ្មីៗរបស់ខ្ញុំ (រួមទាំងអ្នកដែលបានផ្លាស់ប្តូរចូលអ៊ីស្លាមជាច្រើន) បានលួងលោមខ្ញុំពេលខ្ញុំស្ថិតនៅក្នុងផ្លូវជីវិតនៃសាសនាថ្មីរបស់ខ្ញុំ និងប្រតិកម្មដែលខ្ញុំកំពុងជួបប្រទះនៅក្នុងសហគមន៍ដ៏ធំទូលំទូលាយ។ តើមិត្តភក្តិរបស់ខ្ញុំបានគ្រប់គ្រងស្ថានការណ៍នេះដោយរបៀបណា ខ្ញុំមានចម្ងល់? តើពួកគេធ្លាប់មានបទពិសោធន៍ពាក់ហ៊ីហ្សាប (ទទួលក្រម៉ា) នៅទីក្រុងតូរ៉ុនតូដូចខ្ញុំដែរឬទេ? តើមនុស្សពិតជាសម្លឹងមើលរថភ្លើងក្រោមដី ឬកំពុងសម្លឹងមើលអ្វីផ្សេងពីនោះ? ហេតុអ្វីបានជាខ្ញុំត្រូវបានប្រព្រឹត្តដោយការអាណិត /ឬការមើលងាយ? នៅក្នុងអំឡុងពេលដ៏លំបាកនេះ ខ្ញុំកំពុងស្វែងរកប្រធានបទសម្រាប់និក្ខេបបទបណ្ឌិតរបស់ខ្ញុំ។ ទោះបីជាខ្ញុំបានព្យាយាមជៀសវាងវាមួយរយៈពេលក៏ដោយ វាច្បាស់ណាស់ថា ប្រតិកម្មចំពោះហ៊ីហ្សាបទទួលក្បាលគឺជាប្រធានបទដែលសក្តិសមមួយសម្រាប់ការស្រាវជ្រាវនោះ។

* (SAAS)- *សល់លល់ឡហ៊ូអាឡៃហ៊ីវ៉ាសាល់ឡាម* (សូមអល់ឡោះជាម្ចាស់ផ្តល់ភាពសុខសាន្ត និងពរជ័យដល់គាត់) ត្រូវបានពោលនៅពេលឈ្មោះព្យាការីមហាំម៉ាត់ត្រូវបានហៅ ឬពន្លឺឡើង។

ហេតុអ្វីបានជា 'ស្បៃគ្របមុខ' ត្រូវបានគេចាត់ទុកថាជានិមិត្តសញ្ញានៃការជិះជាន់នៅឯលោកខាងលិច? ហេតុអ្វីបានជាលោកខាងលិចហាក់ដូចជាធ្វើបាបសាសនាអ៊ីស្លាម? តើខ្ញុំ និងមិត្តភ័ក្តិរបស់ខ្ញុំអាចមានអារម្មណ៍ត្រូវតាំងចិត្តធ្វើអ្វីមួយ ដែលយើងគិតថាត្រូវតែរំដោះខ្លួនពេលពីការគិតដូច្នេះ និងនៅតែមានជម្លោះបញ្ហាប្រឈមយ៉ាងខ្លាំងជាមួយសង្គមដែលមិនមែនមូស្លីមនៅជុំវិញយើង? ហេតុអ្វីបានជាមនុស្សមិនស្គាល់ទស្សនៈរបស់យើងជាអ៊ីស្លាម និងការទទួលក្រម៉ាហ៊ីយ៉ាបនេះ?

សៀវភៅនេះគឺជាលទ្ធផលប្រៀបដូចការធ្វើដំណើរមួយ ដើម្បីឆ្លើយសំណួរទាំងនេះ។ គោលបំណងចម្បងនៃការគិតឡើងវិញអំពីស្ត្រីមូស្លីម និងស្បៃគ្របមុខ គឺដើម្បីប្រជែងនឹងគំរូលោកខាងលិចដ៏ពេញនិយមដែលគិតស្បៃគ្របមុខ ឬហ៊ីយ៉ាបនោះគឺជាសង្កត់សង្កិន។ អំណះអំណាងដ៏ចម្បងរបស់ខ្ញុំគឺថា គោលគំនិតលោកខាងលិចដ៏ពេញនិយមដែលថាស្បៃមុខ ហ៊ីហ្សាបគឺជានិមិត្តរូបនៃការគៀបសង្កត់របស់ស្ត្រីមូស្លីម វាគឺជារូបភាពដែលបានគិតឡើង ដែលវាមិនតំណាងឱ្យបទពិសោធន៍របស់អ្នកទាំងអស់គ្នាដែលទទួលហ៊ីហ្សាប។ ការសន្មត់គិតបែបនោះតែងតែបម្រើដល់ទីបញ្ចប់សម្រាប់នយោបាយលោកខាងលិច និងវានៅតែបន្តធ្វើដូច្នេះសូម្បីតែនៅចុងសតវត្សរ៍ទី២០ក៏ដោយ។ លើសពីនេះ ខ្ញុំអះអាងថា ការវិនិច្ឆ័យដែលថាហ៊ីហ្សាប ឬស្បៃគ្របមុខគឺជាការគៀបសង្កត់គឺផ្អែកលើការយល់ដឹងរបៀបសេរីនិយមជ្រុលនៃ 'សមភាព' និង 'សេរីភាព' ដែលរារាំងវិធីផ្សេងទៀតនៃការគិតអំពី 'សមភាព' និង 'សេរីភាព' វាផ្តល់នូវវិធីសាស្ត្រវិជ្ជមានបន្ថែមទៀតសម្រាប់ការសញ្ជឹងគិត ដូច្នេះលើការពាក់ស្បៃគ្របមុខឬហ៊ីហ្សាប។

## ជំពូកទី១
## ហ៊ីហ្សាបនៅក្នុងសម័យអាណានិគម

តើនៅពេលណាដែលហ៊ីហ្សាបស្បៃគ្របមុខក្លាយជានិមិត្តរូបនៃការជិះជាន់ នៅលោកខាងលិច? បើទោះបីជាខ្ញុំមិនអាចបញ្ជាក់ពីប្រភពដើមនៃគំនិតនេះក៏ដោយ វាគឺជាភស្តុតាងដែលមាននៅសតវត្សរ៍ទី១៨ ហ៊ីហ្សាបត្រូវបានជនជាតិអឺរ៉ុបយកធ្វើជាទម្លាប់គិតថា វាជាការសង្កត់សង្កិនក្នុងចំណោមប្រជាជនមូស្លីមរួចទៅហើយ។ ស្ត្រីជនជាតិអង់គ្លេស Mary Wortley Montagu ដែលបានធ្វើដំណើរទៅប្រទេសតួកគីជាមួយស្វាមីជាអ្នកការទូត Edward Wortley Montagu នៅក្នុងឆ្នាំ ១៧១៧–១៧១៨ បានជំទាស់នឹងគំនិតដែលថាហ៊ីហ្សាបស្បៃគ្របមុខគឺជាការជិះជាន់សង្កត់សង្កិន។ ដោយបានសាកល្បងទទួលហ៊ីហ្សាបស្បៃគ្របមុខពេលនៅក្នុងប្រទេសទួរគី លោកស្រីបានប្រកែកអះអាងថាវាបានផ្តល់សេរីភាព ព្រោះវាអនុញ្ញាតឱ្យពួកគេចេញទៅក្រៅដោយមិនមានគេស្គាល់។[1] ទោះបីជាយ៉ាងណាក៏ដោយ គំនិតនៃហ៊ីហ្សាបស្បៃគ្របមុខថាជាការគៀបសង្កត់ វាបានសន្មត់ថាជាការផ្តោតអារម្មណ៍ថ្មី និងសំខាន់នៅក្នុងសតវត្សរ៍ទី១៩ ដោយសារពេលនោះជាយុគសម័យនៃអាណានិគមអឺរ៉ុបនៅមជ្ឈិមបូព៌ា។ ដូចដែលលោក Ahmed បង្ហាញនៅក្នុងសៀវភៅរបស់លោកស្រី ដែលថាអាណានិគមនិយមបានប្រើការផ្តោតអារម្មណ៍ថ្មីលើស្ថានភាពរបស់ស្ត្រីដែលជាផ្នែកមួយដើម្បី

បង្ហាញអំពីភាពត្រឹមត្រូវនៃការលុកលុយនិងអាណានិគមរបស់ខ្លួននៅមជ្ឈឹមបូព៌ា។

នៅក្នុងសម័យអាណានិគម ជនជាតិអឺរ៉ុបទាំងប្រុសទាំងស្រីមិនថាពួកគេជាអ្នកអាណានិគម អ្នកធ្វើដំណើរ សិល្បករ អ្នកផ្សព្វផ្សាយសាសនា អ្នកប្រាជ្ញ អ្នកនយោបាយ ឬពួកស្ត្រីនិយម តែងមានគំនិតតែមួយថានោះគឺស្ត្រីមូស្លីមជាត្រូវបានសង្កត់សង្កិនដោយវប្បធម៌របស់ពួកគេ។

ហ៊ីហ្សាប ឬស្បៃមុខត្រូវបានរួមបញ្ចូលជាផ្នែកមួយនៃបញ្ជីស្តង់ដារត្រឹមត្រូវមួយ ដែលត្រូវបានដាក់ថាគឺការគៀបសង្កត់សម្រាប់ស្ត្រីមូស្លីមរួមមាន៖ ពហុពន្ធភាព ភាពឯកា ការលែងលះរបស់បុរសដោយមានភាពងាយស្រួល។ តាមពិត ហ៊ីហ្សាបឬស្បៃមុខបានក្លាយទៅជាពាក្យខ្លីសម្រាប់ប្រើពេលលាបពណ៌ថាជាស្ថានភាពដ៏ថោកទាបរបស់ស្ត្រី និងជាពាក្យប្រៀបធៀប (ឬសញ្ញា) នៃភាពទ្រុឌទ្រោមអន់ខ្សោយ សម្រាប់មជ្ឈិមបូព៌ាទាំងមូល ដែលវាផ្តល់គឺជាចំណីដល់វប្បធម៌អឺរ៉ុបទៅលើទិដ្ឋភាពនៅក្នុងមជ្ឈិមបូព៌ា។[2]

វាមិនមែនគ្រាន់តែលោកខាងលិចទេដែលជឿថាហ៊ីហ្សាបស្បៃគ្របមុខ ជាធម្មជាតិសង្កត់សង្កិនឥស្សរជនជនជាជាតិដើមនៅមជ្ឈឹមបូព៌ាក៏មានទស្សនៈរបស់ពួកគេផ្ទាល់ដូចគ្នាដែរ។ ពួកគេក៏បានជឿជាក់ថាពួកគេដើរថយក្រោយ ស្ត្រីរបស់ពួកគេថោកទាប និងពួកគេគួរតែធ្វើតាមបទបញ្ជារបស់លោកខាងលិចដើម្បីកែលម្អ។ ការលាតត្រដាងនេះបានក្លាយជាភាពបន្ទាន់ដ៏សំខាន់មួយសម្រាប់ឥស្សរជនដែលព្យាយាម ដើរឲ្យទាន់ ជាមួយលោកខាងលិច។ ដូច្នេះ "ហ៊ីហ្សាបឬស្បៃមុខ" បានក្លាយជានិមិត្តសញ្ញាដ៏មានឥទ្ធិពលនៃវឌ្ឍនភាព ឬការថយចុះនៃជាតិមួយពេលនៅមជ្ឈឹមបូព៌ា។[3] ដោយសារវាជាស្ថិតនជួរមុខគេ ទំនើបភាវូបនីយកម្ម សុន្ទរកថាដែលប្រឆាំងហ៊ីហ្សាបឬស្បៃគ្របមុខ ក៏ជាការវាយប្រហារលើផ្នែកទាំងនោះដែលនៅជាប់នឹងការទទួលហ៊ីហ្សាបស្បៃគ្របមុខ និងអត្ថន័យនិមិត្តសញ្ញាចាស់របស់វា (ជានិមិត្តសញ្ញានៃការគោរពសាសនា/ទ្រព្យសម្បត្តិ/ឋានៈ)។[4] សុន្ទរកថាប្រឆាំងហ៊ីហ្សាបបានបើកច្រកឈូងសមុទ្ររវាងប្រជាជននៃប្រជាជាតិមួយ៖ ឥស្សរជនថ្នាក់ដឹកនាំដែលផ្តោតលើតែលោកខាងលិច និងអ្នកផ្សេងទៀតដែលកំពុងទទួលយកវប្បធម៌ពួកអាណានិគម ក៏ដូចជាផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមពីអាណានិគម ប្រៀបធៀបនឹងអ្នកផ្សេងទៀតថាជាអ្នកមានវណ្ណៈទាប មានដូចជាគ្រូបង្រៀនសាសបនា និងអ្នកផ្សេងទៀតថាគឺមិនស៊ីគ្នាទៅនឹងវិធីសាស្ត្រ ឬវប្បធម៌របស់លោកខាងលិច។[5]

ដូច្នេះ គំនិតដែលថាហ៊ីហ្សាបឬ ស្បៃគ្របមុខ គឺជាការគៀបសង្កត់ គឺជាគំនិតដែលកើតចេញពីគំនិតនៃការត្រួតត្រា ឬយ៉ាងហោចណាស់ឆន្ទៈដើម្បីគ្រប់គ្រងពេលប្រទេសដទៃ។ អំណះអំណាងណាដែលជម្រុញគំនិតដែលថាហ៊ីហ្សាប ឬស្បៃមុខជានិមិត្តសញ្ញានៃការគៀបសង្កត់របស់ស្ត្រីមូស្លីម ទាក់ទាញដោយចេតនា ឬដោយភាពមិនដឹងខ្លួន។ ពីសុន្ទរកថានៃទស្សនៈនៃអាណានិគមអឺរ៉ុបដែលលើកឡើងអំពីហ៊ីហ្សាបស្បៃគ្របមុខ។ នោះហើយជាមូលហេតុដែល

ការជជែកវែកញែកគ្នាលើបញ្ហាហ៊ីហ្សាបស្បៃមុខអាចសន្មត់ថា វានឹងមានខឹងសម្បារកើតឡើង។ ហ៊ីហ្សាបឬស្បៃគ្របមុខ ដូចដែលលោកAhmedបានលើកឡើងថា តាំងពីពេលនោះមកគឺនៅសម័យអាណានិគមប្រៀបដូចជា"ការដឹក" ការ "ដឹកទំនិញ" ដែលមានន័យថា [6] គឺការតស៊ូនៅថ្ងៃនេះនៅក្នុងពិភពមូស្លីមលើហ៊ីហ្សាប ដែលវាឆ្លុះបញ្ចាំងពីប្រភេទនៃការបែងចែកថ្នាក់/វប្បធម៌ទាំងនេះ។

## មេតាហ្វីស៊ិកនៃសម័យទំនើប

ប្រសិនបើហ៊ីហ្សាបឬស្បៃគ្របមុខត្រូវបានគេមើលឃើញថាវាជាការជិះជាន់ នៅលោកខាងលិចចាប់តាំងពីទសវត្សរ៍ឆ្នាំ១៧០០ យ៉ាងហោចណាស់មកម្លេះ។ តើវាជាអ្វីអំពីយុគសម័យអាណានិគមសតវត្សរ៍ទី១៩ ដែលនាំមកនូវការចាប់អារម្មណ៍ថ្មីចំពោះហ៊ីហ្សាបឬស្បៃគ្របមុខនេះ? នៅក្នុងជំពូកនេះ ខ្ញុំបានអះអាងថា ជាលក្ខណៈនៃស្បៃគ្របមុខ ឬហ៊ីហ្សាប ដែលវាគឺជាឧបករណ៍រារាំងការសម្លឹងមើលពោលទៅលើស្ត្រី ដែលភាគច្រើននោះគឺការរួមចំណែករបស់វាលើការកាត់បន្ថយការវាយប្រហារ ឬឃាយីចំពោះស្ត្រី។ ទោះបីជាការផុលផុសនៃការលើកឡើងពីហ៊ីហ្សាបបានចាប់ផ្តើមក្នុងអំឡុងពេលនៃសម័យអាណានិគមក៏ដោយក៏ពួកគេបន្តរហូតដល់បច្ចុប្បន្ន និងបានពន្យល់ពីរិះគន់ឬការវាយប្រហារនៅលើការទទួលហ៊ីហ្សាបឬស្បៃគ្របមុខនេះ។ ការវិភាគរបស់ខ្ញុំពង្រីកនូវអំណះអំណាងរបស់ Timothy Mitchellនៅក្នុងអាណានិគមទៅលើអេហ្ស៊ីបអំពីការជួបគ្នារវាងពួកអឺរ៉ុប ស្តីអំពីមេតាហ្វីស៊ិកនៃសម័យទំនើប" ដែលមានបុគ្គលមនុស្សម្នាពីពិភពខាងក្រៅមកទទួលយកបទពិសោធន៍សម្រាប់ខ្លួនឯង និងចាប់យកពិភពសម្ភារៈនិយមដូចជារូបភាព (ពិភពលោកប្រៀបដូចជាតាំងពិព័រណ៍) ជាមួយនឹងមេតាហ្វីស៊ិក ពោលរូបវិទ្យា ដែលមិនមែនមានប្រភពមកពីអឺរ៉ុប ដែលវាមិនត្រូវបានបង្កើតឡើងត្រឹមតែជាសម្ភារៈនិយមដែលត្រូវបានតំណាងជារូបភាពប៉ុណ្ណោះនោះឡើយ។

## ទំនាក់ទំនងជ័ស្នូគ្រស្នាញនៃការទទួលហ៊ីហ្សាបឬស្បៃមុខ

ពោលគឺការគិតដោយពួកលោកខាងលិច។ អ្វីដែលខ្ញុំត្រូវគូសបញ្ជាក់អំពីបទពិសោធន៍នៃសម័យទំនើបពីការតាំងពិពណ៌ពិភពលោកគឺជាអាទិភាពដែលត្រូវបានផ្តល់ឱ្យ ក្នុងការស្វែងរកមើល: "ឥឡូវនេះយើងគឺជាមនុស្សដែលមានបំណង" កាសែត The Times បានសរសេរនៅរដូវក្តៅឆ្នាំ ១៨៥១ នៅក្នុងឱកាសនៃពិព័រណ៍ដ៏អស្ចារ្យមួយ ដោយលើកឡើងថា "យើងចង់ដាក់អ្វីគ្រប់យ៉ាងដែលយើងអាចដាក់នៅក្រោមប្រអប់កញ្ចក់ និងសម្លឹងមើលការបំពេញរបស់យើង"។ [8]

Mitchell កត់សម្គាល់ថានេះគឺជាបទពិសោធន៍ដ៏ទំនើប ជាវត្ថុបំណង អារម្មណ៍ដែលមនុស្សម្នាក់អាចមើលចុះទៅ និងសង្កេតមើលពិភពលោកពីកន្លែងដែលអព្យាក្រឹតមួយ។ តើមានអ្វីកើតឡើងនៅពេលដែលមនុស្សម្នាក់ជួបប្រទះពិភពលោកដែលបង្កើតឡើងដើម្បីបដិសេធការសម្លឹងមើលទៅ ពោលលើទិដ្ឋភាពពិដាក់ស្តែង ការសម្លឹងមើលតម្រូវឱ្យមានទិដ្ឋភាព ដើម្បីមើលឲ្យឃើញ ប៉ុន្តែមិនត្រូវបានមើលតាមការបង្ហាញ ដោយការសន្មត់អវិជ្ជមានរួចជាស្រេចដោយមនុស្សនោះទេសម្រាប់ទស្សនីយភាពមួយ។ វាមិនពិបាកទេក្នុងការមើលភ្លាមៗថាតើអ្នកទស្ស

នាចរអឺរ៉ុបខកចិត្តយ៉ាងណានៅក្នុងសម័យអាណានិគមនៅពេលពួកគេមកដល់មជ្ឈឹមបូព៌ា ជាកន្លែងដែលស្ត្រីបានគ្របមុខរបស់ពួកគេដោយស្បៃមុខនោះ។ ស្ត្រីមិនបង្ហាញខ្លួនដូចជាការតាំងពិព័រណ៍នោះទេ។ ទាំងផ្ទះដែលពួកគេរស់នៅ (បន្ទះឈើមាននៅពីលើបង្អួចដែលមើលទៅតាមផ្លូវ) និងក៏មិនអនុញ្ញាតឱ្យមានការការលាយឡំរវាងបុរសឬស្ត្រីដែរ។ ស្ត្រីដែលបិទបាំងដោយហ៊ីហ្សាបបានផ្ទុយនឹងរាល់លក្ខខណ្ឌដូចជារបស់របរដែល គេតាំងពិព័រណ៍: ពួកគេមិនអាចចេះតែមើលឃើញ ពួកគេមិនអាចមើលឃើញនោះទេប៉ុន្តែអ្វីដែលកំពុងឃើញចំពោះពួកគេ គឺពួកគេមិនមែនដូចជាជារូបភាពក្រដាស់អក្សរដែលអាចអានបាននោះទេ។ ពួកគេគឺជាមនុស្សលោកដែលមានអាថ៌កំបាំង ពោលគឺពួកគេមានវប្បធម៌ដែលមិនព្រមផ្តល់ខ្លួនពួកគេដល់មនុស្សម្នាអាចចេះតែមើលបាន ឬឃើញពួកគេនោះឡើយ។ សម្រាប់ខ្ញុំ នេះជាទិដ្ឋភាពសំខាន់របស់អឺរ៉ុបក្នុងយុទ្ធនាការប្រឆាំងនឹងហ៊ីហ្សាប ការគ្របស្បៃមុខ។ ជនជាតិអឺរ៉ុបបានមកដល់មជ្ឈិមបូព៌ា ជាមួយនឹងចំណេះដឹងប្រកបដោយទំនុកចិត្តនៃការស្ថិតនៅចំណុចកំពូលនៃអរិយធម៌ ប៉ុន្តែវាបែរជាការខកចិត្តសម្រាប់ពួកគេ នៅពេលពួកគេមកដល់នៅមជ្ឈឹមបូព៌ា ពោលព្រោះថាមជ្ឈឹមបូព៌ាមានអរិយធម៌រឹងមាំជាងពួកគេទៅទៀត។ តើមនុស្សម្នាក់អាចមានឋានៈខ្ពង់ខ្ពស់ ឬមានសិទ្ធិអំណាចលើអ្នកដទៃជាង ចំពោះអ្នកដែលខ្លួនមិនអាចស្គាល់បានដោយរបៀបណានោះ (ព្រោះគេមើលមិនឃើញ ចាប់ជារូបភាពមិនបាន) អ្វីដែលមិនអាចមើលឃើញ ចាប់យកជាទស្សនីយភាពបាន មិនអាចគ្រប់គ្រងវាបានឡើយ។ ជាងនេះទៅទៀត ជនជាតិអឺរ៉ុបមានអារម្មណ៍មិនសប្បាយចិត្តចំពោះស្ត្រីដែលទទួលហ៊ីហ្សាបៈ ជនជាតិអឺរ៉ុបដឹងថាពួកគេកំពុងត្រូវបានមើលដោយស្ត្រីដែលខ្លួនឯងមើលមិនឃើញពួកនាង។ នោះបានផ្តល់ឱ្យស្ត្រីនូវអំណាចមួយចំនួនលើជនជាតិអឺរ៉ុប។ នោះគឺជាការបញ្ច្រាសនៃទំនាក់ទំនងដែលរំពឹងទុករវាងថ្នាក់លើអ្នកដែលខ្ពស់ជាង និងអ្នកដែលទាបជាង ដោយការមើលដោយមិនត្រូវបានគេមើលឃើញនោះ។ ដូច្នេះហើយ នេះគឺជាចំណុចសំខាន់នៃអំណះអំណាងរបស់ខ្ញុំ ដែលជនជាតិអឺរ៉ុបបានសងសឹកពោលចំពោះចំណុចនេះ។ ពួកគេបានវាយប្រហារលើស្បៃគ្របមុខ ឬហ៊ីហ្សាប ពួកគេព្យាយាមហែកវាចេញ។ ពួកគេបានព្យាយាមគ្រប់បែបយ៉ាងដែលពួកគេអាចមើលឃើញស្ត្រីទាំងនោះបាន។ ពួកគេបានបង្ហាញស្ត្រីក្នុងរូបគំនូរ រូបថតជាដើម ដោយបង្ហាញរូបអាក្រាត ឬដោយមិនស្លៀកពាក់។ ដូច្នេះហើយពួកគេបានចាប់ផ្តើមយុទ្ធនាការដើម្បីបង្ហាញខ្លួនប្រាណស្ត្រីមូស្លីម។

## សេចក្តីសន្និដ្ឋាន

"មេតាហ្វីស៊ីកនៃសម័យទំនើប " ដែលមានអត្ថន័យត្រូវបានយល់ថាវាគឺជាភាពខុសគ្នារវាងវត្ថុធាតុ និងរចនាសម្ព័ន្ធដែលមិនមែនជាសម្ភារៈដែលវាតំណាងដោយសង្កត់ធ្ងន់លើការសម្លឹងមើលរបស់អ្នកទេសចរជាតិអឺរ៉ុបនៅកាន់មជ្ឈិមបូព៌ា ពួកគេបានវាយប្រហារលើការទទួលហ៊ីហ្សាបរបស់ស្ត្រីមូស្លីម។ ស្បៃគ្របមុខ ឬហ៊ីហ្សាបជារនាំងរាំងជាតិសាសន៍អឺរ៉ុប ដោយបញ្ចប់គម្រោងដែលបានផ្សព្វផ្សាយ ដោយមានទស្សនវិស័យរបស់ពួកគេៈ វាគឺជាភាពអន់ជាងប្រទេសនៅមជ្ឈឹមបូព៌ា និងជាតម្រូវការសម្រាប់លោកខាងលិចដើម្បីអរិយធម៌របស់ពួកគេ។

ទ្រឹស្តីពួកអាណានិគមក៏បានណែនាំគំនិតអំពីភាពអន់ជាងប្រទេសដើមបូព៌ា និងការផ្តោតទៅលើឋានៈរបស់ស្ត្រីជាគោលសម្រាប់វឌ្ឍនភាពទៅក្នុងសុន្ទរកថាទ្រឹស្តីរបស់ពួកអាណានិគម។ ឥស្សរជនជនម្ចាស់ស្រុកដើមរបស់ប្រទេសមជ្ឈឹមបូព៌ាមួយចំនួនបានចាប់យកទ្រឹស្តីរបស់ពួកអឺរ៉ុបលើការអនុវត្តមួយចំនួនដូចជាស្បៃគ្របមុខ ឬហ៊ីហ្សាប នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បី "ធ្វើទំនើបកម្ម"ពោលតាមពួកអឺរ៉ុប។ ចំពោះអត្ថន័យមុនសម័យដើមនៃស្បៃគ្របមុខ ឬហ៊ីហ្សាបវាជានិមិត្តរូបនៃការគោរពបូជា វាជាទ្រព្យសម្បត្តិ ឬជាឋានៈ ប៉ុន្តែវាត្រូវបានបន្ថែមអត្ថន័យដោយថាស្បៃគ្របមុខនោះជានិមិត្តរូបការគៀបសង្កត់ និងការថយក្រោយទៅវិញ។ អត្ថន័យថ្មីមិនបានផ្លាស់ប្តូរអត្ថន័យចាស់បាននោះទេ គ្រាន់តែបានបង្កើតស្រទាប់ថ្មីដែលភ្ជាប់ទៅនឹងទីតាំងរបស់វាប៉ុណ្ណោះ។ ដូច្នេះការបែកបាក់រវាងក្រុមភាគតិចនៃឥស្សរជននិយមបស្ចិមប្រទេសបានកើនឡើង និងភាគច្រើនមិនមែនពួកលោកខាងលិចឡើយ។ ដូចដែលលោកអះម៉ាត់បានអះអាងលើកឡើងនូវសុន្ទរកថាអំពីហ៊ីហ្សាប គឺថាវាជា "ការបង្ខូច" ជាមួយនឹង "ប្រវត្តិសាស្ត្រនៃការត្រួតត្រារបស់ពួកអាណានិគម ការរើបំរាស់ និងការតស៊ូជុំវិញបញ្ហានោះ។[9] បញ្ហាទាំងនេះកំពុងធ្វើឱ្យមានចលនាតស៊ូនៅក្នុងពិភពអ៊ីស្លាមសព្វថ្ងៃនេះ។

## ជំពូកទី២
## ការយល់ឃើញ និងបទពិសោធន៍នៃការទទួលហ៊ីហ្សាប
## នៅទីក្រុងតូរ៉ាន់តូ

ភ្លាមៗបន្ទាប់ពីខ្ញុំចាប់ផ្តើមទទួហ៊ីហ្សាប ក្មេងស្រីសិស្សសាលា២នាក់នៅទីក្រុងម៉ុងរ៉េអាល់ ទីក្រុងកេបិច នៃប្រទេសកាណាដា ត្រឡប់ទៅផ្ទះវិញ ដោយសារតែការបដិសេធមិនព្រមដោះក្រម៉ាឬហ៊ីហ្សាបរបស់ពួកគេនៅក្នុងថ្នាក់រៀន។[10] បញ្ហានៃហេតុការណ៍នេះបានបង្កឱ្យមានការជជែកដេញដោលនៅទូទាំងប្រទេសកាណាដាអំពីអត្ថន័យនៃហ៊ីហ្សាប និងឋានៈរបស់វានៅក្នុងសង្គមនៃប្រទេសកាណាដា។ ភាពចម្រូងចម្រាសនៅប្រទេសកាណាដាអំពីអត្ថន័យនៃការទទូលក្រម៉ា ឬហ៊ីហ្សាបគឺផ្អែកលើការអនុវត្តបែបជននៅខាងក្រៅសង្គមកាណាដា ដែលជនជាតិកាណាដាត្រូវសម្រេចចិត្តថាតើពួកគេនឹងទទួលយកវា ដែលនោះគឺជា"ពិត"។ របាយការណ៍ស៊ើបអង្កេតរបស់គណៈកម្មការផ្សព្វផ្សាយកាណាដា(CBC) បានចោទសួរសំណួរនេះថា៖"តើហ៊ីហ្សាបអាចត្រូវឆ្លងកាត់ការត្រួតពិនិត្យប្រកបទៅដោយប្រសិទ្ធភាពលើភាពជាជនជាតិកាណាដាបានដែរឬទេ?"[11] ដែលនោះមានក្មេងស្រីដែលត្រូវបានបណ្តេញចេញពោលពីសាលាគឺជាជនជាតិកាណាដា (ពីកំណើត)។ គំនិតរបស់ Jeffery Simpson នៅក្នុងសារព័ត៌មាន The Globe and Mail ដែលបានអះអាងថាស្ត្រីមូស្លីមគួរមានសិទ្ធិទទូលហ៊ីហ្សាប ប្រសិនបើពួកគេចង់ទទូលនោះ [12] បង្កឱ្យមានការផ្ទុះឡើងនូវការឆ្លើយតបដោយកំហឹងពីស្ត្រី២នាក់ដែលលើកឡើងថាជាហ៊ីហ្សាប ច្បាស់ណាស់ វាគឺជាសញ្ញានៃការជិះជាន់របស់ស្ត្រីមូស្លីម។[13] អ្វីដែលត្រូវបានគេបិទបាំងនៅក្នុងកិច្ចពិភាក្សាដ៏ពេញនិយមទាំងនេះ នោះគឺសំឡេងនៃស្ត្រីមូស្លីមដែលត្រូវបានគ្របបំបិទខ្លួនឯង។ ជំពូកនេះព្យាយាមដើម្បីបំពេញចន្លោះនោះ ដោយបង្ហាញសំឡេងរបស់មូស្លីមមួយចំនួននៃ

ស្ត្រីជនជាតិកាណាដា ពោលសិទ្ធិរបស់ពួកគេក្នុងការចង់ទទួលហ៊ីហ្សាប។ ខ្ញុំមិននិយាយទូទៅពីទស្សនៈរបស់ពួកគេចំពោះ 'មូស្លីមទាំងអស់' នោះទេ។ គោលបំណងរបស់ខ្ញុំគឺគ្រាន់តែចង់ទទួលបានការយល់ដឹងឱ្យបានហ្មត់ចត់លំអិតអំពីអ្វីដែលស្ត្រីមូស្លីមមួយចំនួនបានគិតអំពីហ៊ីហ្សាប។ ខ្ញុំបានសម្ភាសន៍ស្ត្រីមូស្លីមស៊ុននីចំនួន ១៥នាក់ និងម្នាក់គឺនិកាយអ៊ីស្មាលីម្នាក់ រវាងខែឧសភាដល់ខែកក្កដា ឆ្នាំ១៩៩៦ ដែលរស់នៅក្នុងទីក្រុងតូរ៉ុនតូតំបន់ Ontario នៅប្រទេសកាណាដា។ ក្នុងចំណោម១៦នាក់ មាន៦នាក់ដែលបានផ្លាស់ប្តូរមានជំនឿលើសាសនាអ៊ីស្លាម។ ១០នាក់ពួកគេបានពាក់ហ៊ីហ្សាបគ្រប់ពេល (ក្នុងនោះ៥ជាអ្នកផ្លាស់ប្តូរចូលសាសនាអ៊ីស្លាម) និង៥នាក់ទៀតទទួលហ៊ីហ្សាបនាពេលខ្លះ មានតែស្ត្រី២នាក់ប៉ុណ្ណោះក្នុងចំណោមស្ត្រីទាំងនេះ ដែលមិនមានបំណងចង់ទទួលហ៊ីហ្សាបពេញលេញនៅពេលណាមួយនាពេលអនាគត។ នៅក្នុងចំណោមសាសនិកអ៊ីស្លាមស៊ុននីទាំង១៥នាក់ ពោលមានតែម្នាក់ប៉ុណ្ណោះដែលមិនបានធ្វើការសឡាតប្រចាំថ្ងៃទាំង៥ពេល ដូច្នេះអ្នកដែលនៅសល់គឺ (រួមមាន Noha &Ismaili ដែលសកម្មនៅក្នុងសហគមន៍សាសនារបស់នាងនេះបានធ្វើឱ្យពួកគេក្លាយជាផ្នែកមួយនៃជនភាគតិច ក្នុងចំណោមជនមូស្លីមរស់នៅអាមេរិកខាងជើង ដែលជាអ្នកចូលរួមនឹងវិហារអ៊ីស្លាមសកម្ម (ប្រហែល 1-5 ភាគរយ)។នេះបើយោងតាមអ្នកប្រាជ្ញសាសនាអ៊ីស្លាមនៅអាមេរិកខាងជើង ដើម្បីរក្សាភាពសម្ងាត់របស់អ្នកសម្ភាសន៍របស់ខ្ញុំ ខ្ញុំបានផ្តល់ឱ្យពួកវានូវឈ្មោះក្លែងក្លាយ អ្វីដែលអ្នកដទៃចាត់ទុកថាវាគឺ 'សាសនា'។

## ការយល់ឃើញចំពោះហ៊ីហ្សាប

### ១. អ្វីទៅជាហ៊ីហ្សាប?

ស្ត្រីមូស្លីមទទួលហ៊ីហ្សាបជួនកាលត្រូវបានប្រាប់ដោយជនជាតិកាណាដាថា នេះគឺជាប្រទេសកាណាដា អ្នកមានសេរីភាពនៅទីនេះ អ្នកមិនចាំបាច់ទទួលវាទេ នូវអ្វីដែលនៅលើក្បាលរបស់អ្នក"។ វាជាគោលដៅនៃការបញ្ចេញមតិបែបនេះ វាអាចជាការលេងសើច ឬការចំអន់ចិត្ត ដោយអាស្រ័យលើប្រភេទផ្សេងៗនៅក្នុងព័ត៌មានដែលត្រូវបានចែកចាយ។

Nurជានិស្សិតថ្នាក់បរិញ្ញាបត្រមកពីអាស៊ីខាងត្បូង មានការប៉ះទង្គិចនាថ្ងៃមួយក្នុងហាងកាហ្វេ នៅពេលដែលស្ត្រីចំណាស់ម្នាក់ដើរទៅជិតនាងដែលទាមទារទៅកាន់កញ្ញា Nur ថាហេតុអ្វីបានជាNur "នាំមកនូវភាពឃើតយ៉ាវនៅប្រទេសកាណាដា។" ស្ត្រីរូបនេះបានសង្កត់ធ្ងន់ថាពួកគេបានធ្វើការយ៉ាងលំបាកនៅប្រទេសកាណាដាដើម្បីសិទ្ធិស្ត្រី ហើយចំពោះការទទួលហ៊ីហ្សាបវានឹងបំផ្លាញអ្វីៗទាំងអស់"។ នៅពេលដែលNur បានចង្អុលបង្ហាញថានាងមិនបានធ្វើអ្វីមួយដើម្បីទាក់ទាញការចាប់អារម្មណ៍ឬធ្វើឱ្យខ្លួននាងជា "គោលដៅងាយស្រួលមួយសម្រាប់ការស្អប់ខ្ពើមនោះឡើយ" វាគឺជា "កាតព្វកិច្ចក្នុងសាសនា" ស្ត្រីចំណាស់នោះ"ហាក់ដូចជា ... ស្ងប់ស្ងាត់" ទោះបីជាយ៉ាងណា "គាត់នៅតែមិនជឿ" និងគិតថា Nur មិនគួរទទួលហ៊ីហ្សាប ទោះបីជាមានហេតុផលអ្វីក៏ដោយ។

Nur បានផ្តល់ហេតុផលខាងសាសនានៅពេលព្យាយាមពន្យល់ស្ត្រីកាណាដា ដែលមិនកាន់សា សនាអ៊ីស្លាម ហេតុអ្វីបានជានាងពាក់ហ៊ីហ្ជាបនៅប្រទេសកាណាដា។ អ្នកសម្ភាសន៍របស់ខ្ញុំទាំងអស់ សូម្បីតែ Fatima ដែលកម្របានបិទបាំងទទួលហ៊ីហ្ជាប និងមិនដូចស្ត្រីដទៃទៀតដែលមិនបានបិទបាំងពេញនោះ នៅថ្ងៃណាមួយនោះ បានគិតថា ការទទួលហ៊ីហ្ជាបគឺជាផ្នែកនៃសាសនា ឬកាតព្វកិច្ចក្នុងសាសនា។ នៅពេលដែលខ្ញុំសួរពួកគេថា តើអ្វីបានធ្វើឱ្យពួកគេគិតថាវាជាផ្នែកមួយនៃសាសនានោះ ពួកគេទាំងអស់គ្នាបានឆ្លើយតាមវាក្យខណ្ឌដែលមាននៅក្នុងគម្ពីរអាល់គួរអាន "ព្រះអល់ឡោះជាម្ចាស់ទ្រង់បញ្ជាវានៅក្នុងគម្ពីរអាល់គួរអាន" ជាដើម។ Bassima ដែលជាជនជាតិអង់គ្លេសដែលប្តូរមកសាសនាអ៊ីស្លាម ក៏បានសំដៅទៅលើ "ហាទីស ដែលលើកឡើងថានៅពេលដែលស្ត្រីឈានដល់វ័យពេញវ័យ ពោលមិនអាចឲ្យគេឃើញអ្វីក្រៅពីផ្ទៃមុខ និងបាតដៃឡើយ"។

## ២. ប្រពៃណី (ខ. ការលំអៀងបុរស) អ្វីជាការបកស្រាយបន្ទាញ?

អ្នកប្រាជ្ញស្ត្រីដែលមិនបានបិទបាំងរាងកាយ ដោយបាននិពន្ធស្នាដៃនៃការសិក្សាភាគច្រើនអំពីស្បៃមុខឡើងវិញ។ ពួកគេជាច្រើនបានបញ្ចេញមតិលើការអះអាងរបស់អ្នកសម្ភាសន៍របស់ពួកគេដែលគម្ពីរអាល់គួរអានបានកំណត់ឲ្យគ្របដណ្តប់រាងកាយចំពោះស្ត្រី។ តាមទស្សនៈរបស់អ្នកប្រាជ្ញទាំងនេះ គម្ពីរអាល់គួរអាន តម្រូវឱ្យតែស្លៀកពាក់សមរម្យ មិនមែនជាប្រភេទនៃការបិទបាំងដែលពួកអ្នកអ៊ីស្លាមពិពណ៌នានោះទេ។ ការរៀបចំការសិក្សារបស់ពួកគេតាមរបៀបនេះ គឺជាការរំខានដល់ស្ត្រីដែលពួកគេបានសម្ភាសន៍សម្រាប់អត្ថបទសិក្សារបស់ពួកគេ ព្រោះវាបង្ហាញថាពួកគេអាចបកស្រាយគម្ពីរអាល់គួរអានច្រើនជាងអ្នកសម្ភាសន៍របស់ពួកគេ ពោលពួកគេបកស្រាយតាមតែអំពើចិត្ត។ មធ្យោបាយល្អប្រសើរជាងមុនដើម្បីចូលទៅគៀកនូវភាពខុសគ្នានៅក្នុងការបកស្រាយគឺ ដោយពួកគេយកគំរូតាមការសិក្សារបស់ Karam អំពីស្ត្រីនិយមនៅអេហ្ស៊ីប។ ខណៈពេលដែលពួកគេមិនយល់ស្របនឹងការបកស្រាយរបស់ស្ត្រីអ៊ីស្លាម ថាការគ្របដណ្តប់បិទបាងរាងកាយត្រូវបានតម្រូវនៅក្នុងគម្ពីរអាល់គួរអាន ពួកគេមានអារម្មណ៍ថាមានអត្ថន័យជ្រាលជ្រៅលើការគោរពចំពោះវិធីសាស្ត្ររបស់ពួកគេះវាជាស្ថានភាពទី2 ក្នុងសម័យបុរាណៈ ខ្ញុំមិនអាចធ្វើបានទេ ក្នុងនាមជាស្ត្រីមូស្លីមដែលធំឡើងជាមួយនឹងការកាត់សេចក្តីអ៊ីស្លាម ដើម្បីបដិសេធភាពស្របច្បាប់នៃមូលដ្ឋានអ៊ីស្លាមរបស់អ៊ីស្លាម (នោះគឺជាគម្ពីរអាល់គួរអាន) ខណៈដែលខ្ញុំមិនអាចទទួលយកការបកស្រាយ ដែលពួកគេបានប្រើជាមួយនឹងផលប៉ះពាល់សង្គមជាលទ្ធផលរបស់ពួកគេ និងអ្នកដែលមិនមានជំនឿថាអ្នកផ្សេងទៀតត្រូវបានគេបោកបញ្ឆោតដោយមនសិការមិនពិត។[17]

គំនិតដែលស្ត្រីដែលជ្រើសរើសគ្របដណ្តប់បិទបាំងរាងកាយកំពុងទទួលរងពីមនសិការមិនពិតគឺមានសភាពខ្លាំងនៅលោកខាងលិច។ នៅពេលដែលខ្ញុំចាប់ផ្តើមទទួលហ៊ីហ្ជាប ទៅសាកលវិទ្យាល័យ មិត្តរួមថ្នាក់របស់ខ្ញុំម្នាក់បានប្រាប់មិត្តរបស់ខ្ញុំ "នាងមិនដឹងថានាងត្រូវបានគេជិះជាន់ទេ"? ទោះបីជាយ៉ាងណាក៏ដោយគ្មានស្ត្រីណាម្នាក់អាចជ្រើសរើសការបិទបាំងរាងកាយ ថ្ងៃនេះឡើយជាពិសេសការធំធាត់ឡើង នៅបស្ចិមប្រទេសដោយមិនដឹងខ្លួនអំពីរាល់ការជជែកដេញដោលទាំងនៅក្នុង និងក្រៅសហគមន៍មូស្លីមជុំវិញការអនុវត្តរបស់វា។ ការគ្របដណ្តបបិទបាំងរាង

កាយមានប្រពៃណីដ៏យូរលង់មួយ នៅក្នុងពិភពមូស្លីម ការជជែកវែកញែកនាពេលបច្ចុប្បន្នលើវាគឺថ្មីស្រឡាង ដែលត្រូវបានជំរុញដោយអាណានិគមលោកខាងលិច។ ការរស់នៅក្នុងប្រទេសកាណាដា វាមិនមែនជារឿងងាយស្រួលទេក្នុងការសម្រេចចិត្តទទួលហ៊ីហ្សាប ដោយសារការវាយតម្លៃអវិជ្ជមានរបស់វាដោយសហគមន៍ទូលំទូលាយ និងបទពិសោធន៍នៃការយាយី និងការរើសអើងដែលជាទូទៅកើតឡើងចំពោះអ្នកមូស្លីម ស្ត្រីដែលខ្ញុំបានសម្ភាសន៍មិនបានធ្វើការសម្រេចចិត្តទទួលវាពីមួយថ្ងៃទៅមួយថ្ងៃដោយមិនបានគិតអំពីមូលហេតុ ដែលពួកគេត្រូវទទួលវានោះទេ។ អ្នកប្រាជ្ញនៃចលនាអំពីស្បៃមុខឡើងវិញបានរកឃើញថាមានការលើកទឹកចិត្តខុសៗគ្នាជាច្រើនសម្រាប់ស្ត្រីឱ្យមានទទួលហ៊ីហ្សាប ពីការតស៊ូផ្នែកនយោបាយ រហូតដល់ហេតុផលសេដ្ឋកិច្ច និងការគោរពសក្ការៈ (សូមមើលជំពូកទី៣)។ អ្នកសម្ភាសន៍របស់ខ្ញុំបានពិចារណានូវការបកស្រាយផ្សេងៗនៃគម្ពីរអាល់គួរអាន និងបានជ្រើសរើសអ្វីដែលមានន័យបំផុតសម្រាប់ពួកគេ។ ពួកគេទាំងអស់គ្នាជឿថា វាក្យខណ្ឌគម្ពីរអាល់គួរអានដែលសុំឱ្យស្ត្រីគ្របដណ្ដប់សក់របស់ពួកគេគឺមានអត្ថន័យត្រង់តែម្ដង។

ការយល់ឃើញជាសាធារណៈលើសាសនាអ៊ីស្លាម ពោលពីលោកខាងលិច គឺថាជាសាសនាអាក្រក់ លើកកម្ពស់អំពើហិង្សា និងការជិះជាន់លើស្ត្រី។ សម្រាប់ស្ត្រី ទោះបីយ៉ាងណាក៏ដោយ នៅក្នុងការសិក្សារបស់ខ្ញុំ ហ៊ីហ្សាប គឺជានិមិត្តរូប ទាំងការគៀបសង្កត់ ឬអំពើភេរវកម្ម ប៉ុន្តែ "ភាពបរិសុទ្ធ" "សុភាពរាបសា" "អត្តសញ្ញាណអ៊ីស្លាមរបស់ស្ត្រី" និង "ការស្ដាប់បង្គាប់ ឬការមានជំនឿចំពោះព្រះជាម្ចាស់ និងបញ្ជាក់សក្ខីកម្មថាអ្នកជាមូស្លីម"។ ពួកគេមានអារម្មណ៍សុខសាន្តសេចក្ដីសុខនៅក្នុងទទួលហ៊ីហ្សាប និងរីករាយនឹងការទទួលវា។ ពួកគេជឿជាក់យ៉ាងមុតមាំថា ហ៊ីហ្សាប វាជាអត្ថប្រយោជន៍សម្រាប់សង្គម ពីព្រោះហ៊ីហ្សាប "បានសម្អាត" ទំនាក់ទំនងរបស់ស្ត្រី។ ពួកគេមានអារម្មណ៍ថាត្រូវបានគេចាត់ទុកឲ្យតម្លៃជាមនុស្ស មិនមែនជា "ឧបករណ៍ផ្លូវភេទ"នោះឡើយ និងថាអារម្មណ៍អវិជ្ជមាននៃការច្រណែន និងការឈ្នានីសនឹងថយចុះនៅក្នុងសង្គមដែលស្ត្រីគ្របដណ្ដប់បិទបាំងរាងកាយ។ ប្រសិនបើវិធីសាស្ត្រយ៉េនឌ័រ និងស្ត្រីនិយមនៃបទពិសោធន៍ ដែលមានដូចជា មូលដ្ឋានគ្រឹះសម្រាប់ចំណេះដឹង អត្ថន័យនៃការទទួលហ៊ីហ្សាបទាំងនេះគួរតែត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង និងស្ត្រីមិនត្រូវអនុញ្ញាតឲ្យគេចំអកដោយសារតែការមានជំនឿលើសាសនារបស់ខ្លួនឡើយ។

## ជំពូកទី៣
## ពហុអត្ថន័យរបស់ហ៊ីហ្សាប

ភាពស្មុគស្មាញនៅក្នុងសង្គមអំពីការគ្របដណ្ដប់បិទបាំងរាងកាយមិនត្រូវបានគិតត្រឹមតែជាភាពសាមញ្ញនោះទេ។ នៅលោកខាងលិចដែលតែងតែគិតជានិច្ចថា "ហ៊ីហ្សាបការបិទបាំងរាងកាយ" (តែមួយប្រភេទនោះ) គឺជានិមិត្តសញ្ញាការគៀបសង្កត់លើស្ត្រីក្នុងសាសនាអ៊ីស្លាម។ វត្ថុបំណងរបស់ខ្ញុំនៅក្នុងសៀវភៅនេះគឺដើម្បីប្រឆាំងឆ្លើយតបនឹងទស្សនៈរបស់លោកខាងលិច ជាទូទៅ ដែលគិតថាស្ត្រីគ្រប់រូបទទួលហ៊ីហ្សាប ការធ្វើដូច្នេះដោយសារតែការបង្ខិតបង្ខំ និងថាហ៊ីហ្សាប

តំណាងឱ្យការជិះជាន់របស់ពួកគេនៅក្នុងសាសនាអ៊ីស្លាម។ ជំពូកនេះផ្តោតទៅលើអត្ថន័យជាច្រើនចំពោះហ៊ីហ្ជាប ដើម្បីបង្ហាញដល់មនុស្សម្នាមិនបានអាន ឬយល់តែអត្ថន័យតែមួយអំពីវានោះទេ និងដើម្បីបង្ហាញពីភាពអយុត្តិធម៌ដែលបានធ្វើឡើងចំពោះស្ត្រីមូស្លីមនៅលោកខាងលិចដែលទទួលរងពីការដាក់សម្ពាធដោយសារតែ "ការទទួលហ៊ីហ្ជាបរបស់ពួកគេ" (ឧទាហរណ៍ក្មេងស្រីមូស្លីមដែលត្រូវបានបណ្តេញចេញពីសាលាក្នុងប្រទេសបារាំង និងទីក្រុងកេបិច និងស្ត្រីមូស្លីមដែលរងគ្រោះពីការងារ ដោយការរើសអើង ឬការយាយី ព្រោះតែពួកគេទទួលហ៊ីហ្ជាប)។ ការអនុវត្តរបស់ស្ត្រីម៉ូស្លីម នៅក្នុងប្រទេសផ្សេងទៀតត្រូវបានវិភាគនៅទីនេះដើម្បីបង្ហាញពីអត្ថន័យ ជាច្រើនផ្សេងទៀតអំពីហ៊ីហ្ជាប ដែលវាបានប្រែប្រួលយោងទៅតាមបរិបទ និងភាពខុសគ្នារបស់បុគ្គល។ ខ្ញុំបានសំយោគប្រធានបទស្នូលចំនួន៧ពីការសិក្សាចំពោះការបិទបាំងរាងកាយដើម្បីយល់ពីការលើកទឹកចិត្តខុសៗគ្នារបស់ស្ត្រីសម្រាប់ការគ្របបិទបាំងរាងកាយៈ បដិវត្តន៍ ការបាតុកម្ម រឿងរ៉ាវនយោបាយ សាសនា ការបន្តការចូលប្រើប្រាស់ទីសាធារណៈ ការបង្ហាញអត្តសញ្ញាណផ្ទាល់ខ្លួន ច្បាប់ទម្លាប់ និងរដ្ឋ។ តាមធម្មជាតិមានចំណុចប្រសព្វខ្លះនៅក្នុងចំណោមប្រធានបទដែលខ្ញុំបានកំណត់អត្តសញ្ញាណ និងច្រើនជាងមួយអាចអនុវត្តចំពោះស្ត្រីដូចគ្នា។ នៅក្នុងផ្នែកនេះដើម្បីអនុវត្ត ខ្ញុំបានបង្ហាញប្រធានបទនៃការបិទបាំងរាងកាយដែលដកយកចេញពីការសិក្សាទាំងនេះ។ បន្ទាប់មកខ្ញុំបានមើលទៅលើអត្ថន័យដែលប្រព័ន្ធផ្សព្វផ្សាយលោកខាងលិចដែលគេនិយមហៅថាហ៊ីហ្ជាប។ នេះវាអនុញ្ញាតបង្ហាញឱ្យឃើញថា រូបភាពនៃហ៊ីហ្ជាបនៅលោកខាងលិចដែលបង្កើតដោយប្រព័ន្ធផ្សព្វផ្សាយគឺមានភាពអវិជ្ជមានច្រើនលើសលប់ ដោយមានការពាក់ព័ន្ធតិចតួចទៅនឹងទស្សនៈរបស់ស្ត្រី ពេលពួកគេលាបពណ៌អាក្រក់លើអ៊ីស្លាម។

## មូលហេតុនៃការបិទបាំងរាងកាយ

(1) បដិវត្តន៍ប្រឆាំងរបបដឹកនាំ: ក្នុងអំឡុងពេលប្រយុទ្ធរបស់អាល់ហ្សេរី ដើម្បីឯករាជ្យនៅទសវត្សរ៍ឆ្នាំ 1950 និងនៅអ៊ីរ៉ង់នៅក្នុងទសវត្សរ៍ឆ្នាំ 1970 ស្ត្រីដែលពីមុនមិនបានបិទបាំងរាងកាយនោះ បានទទួលហ៊ីហ្ជាបស្បៃមុខ /ក្រម៉ាទៅជួយផ្តួលរំលំរដ្ឋាភិបាលដែលជិះជាន់។[18] កន្សែងបង់ក បង្ហាញថាមួយប្រឆាំងនឹងអាណានិគមនិយម ឬប្រឆាំងនឹងរបបផស្សរជនដែលមានសាមានចិត្តនឹងលោកខាងលិច និងអ្វីៗទាំងអស់ដែលខ្លួនពួកគេបានធ្វើសម្រាប់ពួកអាណានិគម។

(2) ការបាតុកម្មនៅក្នុងនយោបាយៈ ស្ត្រីទទួលហ៊ីហ្ជាបវាជាការតវ៉ាក្នុងរូបភាពនយោបាយប្រឆាំងនឹងកម្មវិធីភាវូបនីយកម្មរបស់បស្ចិមប្រទេស និងពួកនិយមបស្ចិមប្រទេសលោកខាងលិចដើម្បីបង្ហាញសញ្ញាថាពួកគេមិនសប្បាយចិត្តនឹងបច្ចុប្បន្នស្ថានភាពនយោបាយ ទាំងគោលនយោបាយដែលរដ្ឋអនុវត្ត /ឬជាមួយនឹងវិស័យ "ពាណិជ្ជកម្ម បច្ចេកវិទ្យា នយោបាយ និងសង្គម" ការលុកលុយប្រទេសរបស់ពួកគេដោយលោកខាងលិច។[19]

(3)សាសនាៈ ជាផ្នែកមួយ និងជាការតវ៉ានយោបាយប្រឆាំងនឹងភាវូបនីយកម្មលោកខាងលិច និងភាវូបនីយកម្មខាងលោកិយនិយមគឺជាការថ្កោលទោសអំពីសាសនាអ៊ីស្លាម ដែលជាជម្រើស

នយោបាយ សង្គម និងជាប្រព័ន្ធសេដ្ឋកិច្ចដ៏វិជ្ជមាន។ ស្ត្រីជាច្រើនបានសម្រេចចិត្តគ្របដណ្ដប់បិទបាំងរាងកាយដោយហ៊ីហ្ជាបផ្អែកទៅលើការអំពាវនាវរបស់ចលនាអន្តរជាតិមួយនេះ សម្រាប់បុរស និងស្ត្រីបង្ហាញឲ្យឃើញថាជា 'សំលៀកបំពាក់អត្តសញ្ញាណអ៊ីស្លាម' ។[20]

(3.1) ការធ្វើឱ្យសង្គមកាន់តែប្រសើរឡើង៖ រួមជាមួយនឹងប្រធានបទនៃការបដិសេធលើភាវូបនីយកម្មលោកខាងលិច និងភាវូបនីយកម្ម និងការទទួលយកសាសនាអ៊ីស្លាម, វាគឺជាការរីកសាយមួយដែលស្ត្រីដែលទទួលហ៊ីហ្ជាប មានអារម្មណ៍ថាពួកគេកំពុងតែសកម្មក្នុងការកែលម្អសង្គម។ នៅក្នុងទស្សនៈនេះ ហ៊ីហ្ជាប វាបានតំណាងឱ្យកម្រិតនៃសង្គមរស់នៅ។[21] លោកWilliams បានរកឃើញថាស្ត្រីនៅក្នុងប្រទេសអេហ្ស៊ីបមានអារម្មណ៍ថាពួកគេទទួលហ៊ីហ្ជាបនោះ វាគឺជាមធ្យោបាយដោះស្រាយបញ្ហាសង្គម ដើម្បីបញ្ឈប់ពីការបែកបាក់គ្នា (ភាពរលាយរលត់ ការបែកបាក់នៅក្នុងសង្គម)។ [22]

(4) ការបន្តចូលទៅក្នុងទីសាធារណៈ៖ មិនមែនស្ត្រីទាំងអស់ដែលបានចាប់ផ្តើមគ្របដណ្ដប់បិទបាំងរាងកាយហ៊ីហ្ជាបក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះទាំងអស់នោះទេ ពោលពួកគេគ្មានការកាត់ទោសពីការបំពានច្បាប់សាសនានោះឡើយនាពេលនោះ។ ស្ត្រីទាំងនេះ ដែលខ្លះមិនដែលថ្វាយបង្គំផងក៏បានយល់ឃើញឃើញថា ហ៊ីហ្ជាបវាបានជួយសម្រួលដល់ការចូលទៅក្នុងទីសាធារណៈ: ដូចជាការស្វែងរកការងារធ្វើ ទទួលបានគោរពឲ្យតម្លៃ និងប្រយុទ្ធប្រឆាំងនឹងការបៀតបៀនរបស់បុរស។[23]

(5) ការបង្ហាញអត្តសញ្ញាណផ្ទាល់ខ្លួន៖ ហេតុផលមួយទៀតសម្រាប់ការទទួលហ៊ីហ្ជាប ជាពិសេសសម្រាប់ស្ត្រីមូស្លីមនៅលោកខាងលិចគឺដើម្បីបង្ហាញអំពីអត្តសញ្ញាណផ្ទាល់ខ្លួន ស្រដៀងទៅនឹង Nadia ជាស្ត្រីជនជាតិអង់គ្លេសអាស៊ីជំនាន់ទី2 ដែលចាប់ផ្តើមបិទបាំងរាងកាយនៅពេលពួកនាងមានអាយុ16 ឆ្នាំ៖ "... ការពាក់ស្បៃមុខហ៊ីហ្ជាបធ្វើឱ្យខ្ញុំមានអារម្មណ៍ពិសេស វាជាប្រភេទផ្លាកសញ្ញានៃអត្តសញ្ញាណ និងជាសញ្ញាដែលបង្ហាញថាសាសនាគឺសំខាន់សម្រាប់ខ្ញុំ"។[24]

(6)ទំនៀមទំលាប់៖ ស្ត្រីមូស្លីមជាច្រើនទទួលហ៊ីហ្ជាបវាជាមធ្យោបាយមួយនៃការគោរពប្រពៃណី និងវប្បធម៌របស់គ្រួសារ ឬសង្គមរបស់ពួកគេ។ គ្រូបង្រៀនអាយុ 35 ឆ្នាំមកពីប្រទេសអារ៉ាប៊ីសាអូឌីតដែលមានបរិញ្ញាបត្រផ្នែកអប់រំ មកពីសហរដ្ឋអាមេរិកបាននិយាយថា: "ចាស ខ្ញុំពាក់ស្បៃមុខ ឬហ៊ីហ្ជាប។" 'តើអ្នកផ្អែកលើការផ្តន្ទាទោសរបស់អ្នកលើអ្វី?' ពោលចំពោះការចោទប្រកាន់លើហ៊ីហ្ជាប [AlMunajjed] សួរ។ 'ខ្ញុំជាប់ទៅនឹងប្រពៃណីរបស់ខ្ញុំ។ ការពាក់ស្បៃមុខ ឬហ៊ីហ្ជាបគឺជាផ្នែកមួយនៃអត្តសញ្ញាណរបស់មនុស្សម្នាក់នៃការជាស្ត្រីអារ៉ាប៊ីសាអូឌីត។ វាគឺជាភស្តុតាងច្បាស់លាស់នៃអត្តសញ្ញាណរបស់មនុស្សម្នាក់ជាមួយនឹងបទដ្ឋាន និងតម្លៃនៃវប្បធម៌របស់អារ៉ាប៊ីសាអូឌីត... និងខ្ញុំនឹងបង្រៀនកូនស្រីរបស់ខ្ញុំផងដែរដើម្បីទទួលវា។"[25]

(7) តម្រូវការច្បាប់រដ្ឋ៖ ការគ្របដណ្ដប់ត្រូវបានទាមទារដោយច្បាប់រដ្ឋដូចជានៅអ៊ីរ៉ង់ក្រោយបដិវត្តន៍ឆ្នាំ1979 និងអាហ្វហ្គានីស្ថាន បន្ទាប់ពីការចូលកាន់អំណាចឆ្នាំ1998 ដោយពួកតាលីបង់។

វាងាយស្រួលណាស់ក្នុងការបង្ហាញអំពីភាពខុសគ្នារវាងភាពស្មុគស្មាញនៅសង្គមពីការលើកទឹកចិត្ត និងអត្ថន័យនៃការគ្របបិទបាំងរាងកាយ និងស្តង់ដារូបភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់លោកខាងលិចអំពីការលើកទឹកចិត្ត និងអត្ថន័យនៃការគ្របបិទបាំងរាងកាយរបស់ស្ត្រី។ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយរបស់លោកខាងលិច ហ៊ីហ្សាបតំណាងឱ្យការគៀបសង្កត់ និងជាពាក្យខ្លី តែមានន័យសម្រាប់ភាពភ័យរន្ធត់ទាំងអស់នៃសាសនាអ៊ីស្លាម (ឥលូវនេះដែលវាគឺជាមូលដ្ឋានគ្រឹះនៃសាសនាអ៊ីស្លាម)ថាជា: អំពើភេរវកម្ម អំពើហឹង្សា ព្រៃផ្សៃ និងការដើរថយក្រោយ។ នេះគឺជាន័យការសន្មត់ដែលបានកំណត់ទុកជាមុនដែលព័ត៌មានលម្អិតជាក់ស្តែងត្រូវបានធ្វើឡើង ដើម្បីឱ្យសមស្របទៅនឹងអ្វីដែលពួកគេលាបពណ៌អាក្រក់លើអ៊ីស្លាម។

ដូចនៅក្នុងសម័យអាណានិគមដែរ នៅពេលដែលស្បៃមុខ ឬហ៊ីហ្សាបគឺជាពាក្យប្រៀបធៀបនៃសម្រាប់ប្រទេសទិសបូព៌ាទាំងមូល នៅក្នុងទសវត្សរ៍ឆ្នាំ1990 ពាក្យ "ស្បៃមុខ" ឬហ៊ីហ្សាបគឺពាក្យខ្លីសម្រាប់តំណាងនៃភាពភ័យរន្ធត់ទាំងអស់នៃលទ្ធិអ៊ីស្លាមនិយម។ ចំណងជើងដែលថា: "ការគំរាមកំហែងនៃសាសនាអ៊ីស្លាម" [26] "ស្ត្រីនៃស្បៃគ្របមុខ: ពួកសកម្មប្រយុទ្ធអ៊ីស្លាមបានជំរុញស្ត្រីឱ្យត្រឡប់ទៅអាយុនៃកាតព្វកិច្ចឃោជាជាផ្លូវការ" [27] "Foulard. Le Complot: Comment les Islamistes Nous Infiltrent [The Veil. The Plot: How the Islamists are Infiltrating Us]"[28] "ការគំរាមកំហែងនៃស្បៃមុខរបស់អ៊ីស្លាម"[29] "សកម្មភាពនៃជំនឿ ឬការគំរាមកំហែងដល់សង្គម?" [30] "ការគំរាមកំហែងស្បៃគ្របមុខរបស់មូស្លីមចំពោះភាពសុខដុមរមនានៅក្នុងសាលារៀនបារាំង, រដ្ឋមន្ត្រីបាននិយាយថា" [31] "ច្បាប់ថ្មី៖ ពាក់ស្បៃគ្របមុខ និងភាពនៅរស់រៀន" [32] "ស្ត្រីដែលជាប់នៅពីក្រោយស្បៃមុខ" [33]។

ដូច្នេះហើយហ៊ីហ្សាប ត្រូវបានផ្សារភ្ជាប់ទៅនឹងការអះអាងពោលដោយលាបពណ៌អំពីភាពអន់ខ្សោយរបស់ស្ត្រីនៅក្នុងសាសនាអ៊ីស្លាម។ "ស្បៃមុខ" ត្រូវបានគេសន្មត់ថាជា "ផ្លាកសញ្ញានៃការគៀបសង្កត់ស្ត្រី" [34] ការបង្ខំលើស្ត្រីដែលមិនចង់ពាក់វាដោយវិធីសាស្ត្រផ្សេងៗ សំណូកទិញទឹកចិត្ត[35] ឬការគំរាមកំហែង និងមានទៅដោយអំពើហិង្សាជាក់ស្តែង។[36] ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលយើងបានឃើញខាងលើ ស្ត្រីជាច្រើននៅក្នុងប្រទេសមូស្លីម ទទួលហ៊ីហ្សាបដោយស្ម័គ្រចិត្ត និងដោយមិនមានការបង្ខំ។ នៅក្នុងការសិក្សាពោលដោយមានចេតនាលាបពណ៌ដោយ Scroggins, Goodwin's និង Brooks បានឲ្យដឹងថាស្ត្រីទាំងនេះបានឆ្លងកាត់វាដោយការបោកបញ្ឆោត ឬភាពចម្លែក ហើយអាក្រក់បំផុត ដោយសារមនោគមវិជ្ជាអ៊ីស្លាមមានទំនួលខុសត្រូវស្មើគ្នា និងទទួលខុសត្រូវដូចបុរសសម្រាប់ការគាំទ្រមនោគមវិជ្ជាប្រឆាំងនឹងស្ត្រីពោលនេះជាការាបពណ៌របស់ប្រព័ន្ធផ្សព្វផ្សាយលោកខាងលិច។[37] យុវជនដែលមានភាពលេចធ្លោក្នុងការសិក្សាលើការសិក្សាដែលបានពិភាក្សាខាងលើ ត្រូវបានបង្ហាញនៅក្នុងការសិក្សារបស់ Goodwin ដែលបង្ហាញថាពួកគេងាយទាក់ទាញទៅនឹង "ភាពជ្រុលនិយម"ដោយសារអាយុ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេ។ "ភាគច្រើន" ពួកគេគេចពីការសម្ភាសន៍។[38]នៅក្នុងស្នាដៃរបស់ Brooks បានសរសេរថា ពួកគេពោលស្ត្រីបានបង្ហាញជាដំណឹងថាអនាគតដ៏អាក្រក់ដែល

ដឹកនាំប្រទេសរបស់ពួកគេ ឲ្យដើរថយក្រោយមិនទាន់សម័យកាល។ គ្មានការព្រមាន / ឬភាពខុសប្លែកគ្នានៃការសិក្សាដោយអ្នកប្រាជ្ញរបស់លោកខាងលិច ដែលមានដូចជាការសង្កេតរបស់ Macleod ថាស្បៃមុខក្នុងទម្រង់ថ្មីស្ថិតនៅទីក្រុងគែរដែលប្រជាជនថ្នាក់ទាបទទួលវា មិនត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងចលនាអ៊ីស្លាមនៅក្នុងប្រទេសអេហ្ស៊ីបនោះទេ ឬការសង្កត់ធ្ងន់របស់ Zuhur និង Rugh លើការគោរពសក្ការៈ[39] មិនមែនជាលក្ខខណ្ឌសេដ្ឋកិច្ចសង្គម ឬ ការយល់ឃើញរបស់ Brenner ចំពោះស្ត្រីជនជាតិជ្វាឥណ្ឌូនេស៊ីថាស្ត្រីដែលមើលឆ្ពោះទៅមុខដោយមានហេតុផល និងឆ្ពោះទៅសម័យទំនើបត្រូវអប់រំខ្លួនឯង និងកែលម្អសង្គមរបស់ពួកគេឡើងវិញ ពោលទាំងនេះគឺជាទស្សនៈសិក្សារបស់ពួកអ្នកប្រាជ្ញលោកខាងលិចដែលមិនចូលចិត្តអ៊ីស្លាម។[40]

## ជំពូកទី៤

## Mernissiនិងសុន្ទរកថាអំពីស្បៃគ្របមុខ

ស្ត្រីនិយមជនជាតិម៉ារ៉ុក សៀវភៅចំនួន២ក្បាលរបស់ Fatima Mernissi នោះគឺសៀវភៅ លើសពីស្បៃគ្របមុខ និងសៀវភៅ The Veil និង Male Elite ត្រូវបានពិភាក្សាយ៉ាងទូលំទូលាយនៅលោកខាងលិចអំពី 'អត្ថន័យ' នៃគ្របមុខ។[41] នៅក្នុងសៀវភៅទាំង២ក្បាលនេះ Mernissi បានអះអាងថាស្បៃគ្របមុខគឺជានិមិត្តសញ្ញានៃសិទ្ធិអំណាចបុរសដ៏អយុត្តិធម៌លើស្ត្រី។ សៀវភៅរបស់ខ្ញុំនេះមានគោលបំណងបង្ហាញភាពពិតពីការចោទប្រកាន់លើការពាក់ស្បៃគ្របមុខថាវាជាការគៀបសង្កត់ ជាការរិះគន់ សៀវភៅនេះនឹងបដិសេធអំណះអំណាងចម្បងរបស់ Mernissi ដែលមាននៅក្នុងសៀវភៅទាំង២របស់គាត់គឺវាពិតជាមានភាពចាំបាច់ណាស់។

### Mernissi និងវិធីសាស្ត្រ

ការវង្វេងគ្រោះផ្ទាល់ខ្លួនដែល Fatima Mernissi ហាក់ដូចជារីកសាយធំឡើងនៅក្នុងប្រទេសម៉ារ៉ុក គឺវាមិនឆ្ងាយពីស្នាដៃសៀវភៅនៃការសរសេរភាគច្រើនរបស់គាត់ឡើយ។ រឿងខ្លីមួយពីជីវប្រវត្តិរបស់ Mernissi វាបានបំភ្លឺទំនាក់ទំនងដែលធ្វើឱ្យគាត់គ្របដណ្តប់បិទបាំងរាងកាយបានយ៉ាងល្អ។ នៅក្នុងកំឡុងសង្គ្រាមលោកលើកទី2 នៅពេលដែលគាត់មានអាយុ៩ឆ្នាំ គាត់ និងបងប្អូនជីដូនមួយរបស់គាត់ ត្រូវបានគេសន្និដ្ឋានថាពួកគាត់បានផ្លាស់ប្តូរពណ៌សក់ ឬធ្វើការបិទបាំងវាដើម្បីការពារខ្លួនពីហ៊ីត្លែរ ដែល "ស្អប់មនុស្សសក់ពណ៌ខ្មៅ និងភ្នែកខ្មៅ និងកំពុងទម្លាក់គ្រាប់បែកពីលើយន្តហោះ គ្រប់ទីកន្លែងដែលប្រជាជនសក់ខ្មៅត្រូវបានគេប្រទះឃើញ។"[42] Mernissi បានចាប់ផ្តើមពាក់អាវមួយរបស់ម្តាយនាង នឹងគ្របដោយក្រមា ម្តាយរបស់គាត់ខឹងដោយបាននិយាយថា "កុំយកក្បាលឯងមក!" ម្តាយស្រែក។ "ឯងយល់ចិត្តយើងទេ? យើងកំពុងតែប្រឆាំងនឹងការគ្របស្បៃមុខ ពោលហ៊ីហ្ជាប ឯងទទួលវាមួយនៅពីលើ! តើនេះជាអ្វី មិនសមហេតុសមផល?... ទោះបីជាហ៊ីត្លែរ ជាស្តេចដ៏មានមហិទ្ធិឫទ្ធិនៃអាឡឺម៉ង់ ស្ថិតនៅពីក្រោយ

ឯងក៏ដោយ គាត់បាននិយាយថា "អ្នកគួរតែប្រឈមមុខនឹងគេដោយសក់របស់អ្នកបើកចំហ ការគ្របក្បាល និងលាក់ខ្លួនមិនអាចជួយបានទេ។ ការលាក់បាំងមិនអាចដោះស្រាយបញ្ហារបស់ស្ត្រីបានទេ។ វាគ្រាន់តែកំណត់ថាស្ត្រីជាជនរងគ្រោះដោយងាយ។ ជីដូនរបស់អ្នក និងយើងបានរងទុក្ខគ្រប់គ្រាន់ពីការគ្របក្បាលនេះ។យើងដឹងថាវាមិនអាចទៅរួចទេខ្ញុំចង់ឲ្យកូនស្រីរបស់ខ្ញុំក្រោកឈរឡើង ហើយដើរលើភពផែនដីរបស់អល់ឡោះ ដោយសម្លឹងមើលផ្កាយ ពោលសេរី»។[43]

ប្រឈមមុខនឹងបញ្ហានេះ តើក្មេងៗអាចអភិវឌ្ឍន៍អ្វីក្រៅពីអាកប្បកិរិយាដែលមិនច្បាស់លាស់ (ឬអវិជ្ជមាន) នៅក្នុងការគ្របដណ្តប់បិទបាំងបានទេ? តើនារីវ័យក្មេងអាចសម្រេចចិត្តថាចង់បិទបាំងដោយមិនត្រូវគេមើលឃើញថាវាគឺជាការដើរថយក្រោយ ឬប្រឆាំងនឹងសង្គមជាតិខ្លួន? Mernissi គឺជាក់ស្តែងនៅតែរងទុក្ខដោយការចងចាំទាំងនេះ ហើយខ្លួនទាំងមូលរបស់នាងច្បាស់ជាស្វែងរកមូលហេតុនៃការឈឺចាប់របស់នាង វាជាមធ្យោបាយផ្លាស់ប្តូរ និងការដោះស្រាយ។ តើអ្នកណាមិនថ្កោលទោសប្រព័ន្ធបែបនេះ? ស្ត្រីក្នុងវ័យរបស់នាង ដែលត្រូវបានឲ្យស្ថិតនៅក្នុងភាពមិនចេះអក្សរ ត្រូវបិទបាំងមុខរបស់ពួកគេ (niqab) នៅពេលដែលពួកគេត្រូវបានអនុញ្ញាតឱ្យទៅខាងក្រៅ។ ការបិទបាំងរបស់ពួកគេជាមួយនឹងការគៀបសង្កត់របស់ស្ត្រីហាក់ដូចជាបង្ហាញឱ្យឃើញពីខ្លួនឯងរបស់នាងផ្ទាល់។ បញ្ហាគឺថា Mernissi ចាត់ទុកបទពិសោធន៍រងគ្រោះរបស់នាងនៃការបិទបាំងនៅក្នុងប្រព័ន្ធនៃសង្គមនប្រទេសម៉ារ៉ុកថាជា 'បទពិសោធន៍' នៃស្បៃគ្របមុខតែម្តង ជា 'អត្ថន័យ' ពីកំណើត ឬភាពពិតនៃស្បៃគ្របមុខ។ ដូចដែលខ្ញុំបានពន្យល់លម្អិតបន្ថែមទៀតនៅពេលក្រោយ Mernissi បរាជ័យក្នុងការទទួលស្គាល់ច្បាប់នៃការអនុវត្តអ៊ីស្លាមជុំវិញការគ្របស្បៃមុខ (ដូច្នេះហើយអត្ថន័យរបស់វាដូចដែលបានពិពណ៌នានៅក្នុងជំពូកទី3) និងពហុវចនាធិប្បាយអ៊ីស្លាមជុំវិញស្បៃគ្របមុខ។ នាងបន្តវិធីសាស្ត្រប្រវត្តិសាស្ត្រដែលស្មើនឹងប្រព័ន្ធសង្គម/នយោបាយ/សេដ្ឋកិច្ចម៉ារ៉ុកនៅសតវត្សរ៍ទី20 ជាមួយនឹងប្រព័ន្ធអារ៉ាប់នៅសតវត្សរ៍ទី7 ជាមួយនឹងគំនិតដែលថាអ្វីដែលបណ្តាលឱ្យប្រទេសម៉ារ៉ុកកើតមានឡើងនៅសតវត្សរ៍ទី20 គឺជាអ្វីដែលព្យាការីមហាំម៉ាត់ ស្រមៃថាវាជាឧត្តមគតិវិជ្ជមាននៃសាសនាអ៊ីស្លាម។ នាងក៏បានចាត់ទុកស្មើគ្នាដែរនូវអ្វីដែលជាលទ្ធផលនៅប្រទេសម៉ារ៉ុកជាមួយនឹងអ្វីដែលជាលទ្ធផលកើតមាននៅក្នុងពិភពមូស្លីមទាំងមូល ដល់កម្រិតដែលនាងពិភាក្សាអំពីអត្ថន័យនៃការលាក់បាំងនៅក្នុងសណ្តាប់ធ្នាប់សង្គមមូស្លីមដូចជាប្រទេសឥណ្ឌូនេស៊ី បង់ក្លាដែស ម៉ារ៉ុក អារ៉ាប៊ីសាអូឌីតជាដើម។ ប្រដូចប្រព័ន្ធដូចគ្នាបេះបិទទៅនឹងសហគមន៍មូស្លីមដំបូងបំផុតនៅអារ៉ាប់នៅសតវត្សរ៍ទី៧ថែមទៀត។[44]

ដូច្នេះ ការខ្វែងគំនិតគ្នាដ៏ធំរបស់ខ្ញុំជាមួយ Mernissi មាន២៖ (1) វិធីសាស្ត្រប្រវត្តិសាស្ត្រចំពោះអត្ថន័យនៃនិមិត្តសញ្ញានៃសាសនាដែលបរាជ័យក្នុងការកំណត់បរិបទអំពីរបៀបដែលមនុស្សអនុវត្តន៍សាសនាអ៊ីស្លាមខុសគ្នាក្នុងពេលវេលានិងទីកន្លែងផ្សេងៗគ្នា។និង(2) វិធីសាស្ត្រកាត់បន្ថយពោលដោយមិនទទួលស្គាល់ភាពដ៏ច្រើននៃសុន្ទរកថា ឬច្បាប់កំណត់ជុំវិញការគ្របស្បៃមុខ។ ដើម្បីប្រឆាំងនឹងគំរូអវិជ្ជមានដែលថា ហ៊ីហ្សាបជានិមិត្តរូបនៃការជិះជាន់របស់សាសនាអ៊ីស្លាមចំពោះស្ត្រី វាពាក់ព័ន្ធនឹងសំណួរសួរថាតើ 'សាសនាអ៊ីស្លាម' តម្រូវឱ្យសង្គមមួយប្រភេទដែល

Mernissi ថ្កោលទោសថាជាអរិភាពចំពោះស្ត្រី ឬទស្សនៈនៃសង្គមផ្សេងទៀតដែលផ្តល់ផលជាង សម្រាប់ស្ត្រី ពោលអ៊ីស្លាមមិនជំរុញឲ្យមានសង្គមនិយមជ្រុលដូចMernissi ថ្កោលទោសនោះឡើយ ប៉ុន្តែការទទួលហ៊ីហ្សាបត្រូវតែអនុវត្តន៍។ នៅក្នុងជំពូកនេះ ខ្ញុំបដិសេធថា អំណះអំណាងរបស់ Mernissi អំពីទស្សនៈរបស់សាសនាអ៊ីស្លាមចំពោះស្ត្រីគឺ ផ្ទុយពីប្រភពនៃសាសនាអ៊ីស្លាមគម្ពីរអាល់គួរអាន និងហាទីស(ការមានប្រសាសន៍របស់ព្យាការីមូហាំម៉ាត់) ។ ការជជែកវែកញែករបស់ខ្ញុំជាមួយ Mernissi មិនមែនដើម្បីបដិសេធថាសង្គមមូស្លីមរួមបញ្ចូលការអនុវត្តការគាបសង្កត់ ឬសុន្ទរកថាលើស្ត្រីនោះទេ។ ជម្លោះរបស់ខ្ញុំជាមួយនាងគឺអំពីសាសនាអ៊ីស្លាមធម្មតា (តើទស្សនៈយល់ឃើញរបស់អាល់គួរអានប្រឆាំងនឹងស្ត្រីមែនឬអត់?) ការបកស្រាយនៃចក្ខុវិស័យរបស់គម្ពីរអាល់គួរអាន ដែលអំណោយផលដល់ស្ត្រីប្រឆាំងនឹងទស្សនៈរបស់ Mernissi និងការបកស្រាយអាល់គួរអានផ្សេងទៀតដែលមិនមានលក្ខណៈគៀបសង្កត់លើស្ត្រី។

## ស្ត្រី និងបញ្ហាភេទនៅក្នុងអាល់គួរអាន និងស៊ុនណះ

ករណីរបស់ Mernissi ប្រឆាំងនឹងស្បៃគ្របមុខហ៊ីហ្សាបគឺផ្អែកលើការសន្និដ្ឋានរបស់នាងដែលថា សាសនាអ៊ីស្លាមចាត់ទុកការរួមភេទរបស់ស្ត្រីថាមានគ្រោះថ្នាក់ ដូច្នេះចាំបាច់ត្រូវមានការគ្រប់គ្រង។ នាងបានអះអាងបន្ថែមទៀតថា សាសនាអ៊ីស្លាមចាត់ទុក 'ភាពជាស្ត្រី' ថាជាការប្រឆាំងនឹងទេវភាព ឬជាការប្រមាថ ហើយថាសាសនាអ៊ីស្លាមគឺប្រឆាំងនឹងការស្រឡាញ់ភេទផ្ទុយគ្នារវាងប្តីប្រពន្ធ។ ស្ត្រីគំរាមកំហែងទំនាក់ទំនងរបស់បុរសចំពោះព្រះជាម្ចាស់ដូច្នេះត្រូវតែបិទបាំងផ្តាច់ខ្លួន និងដកចេញពីសហគមន៍អ៊ីស្លាម។[45]

គ្មានអំណះអំណាងណាមួយអាចត្រូវបានគាំទ្រដោយការអានយ៉ាងយកចិត្តទុកដាក់ ពីគម្ពីរអាល់គួរអាន និងស៊ុនណះនោះឡើយ។ ដូចកំណត់សម្គាល់ សាសនាអ៊ីស្លាមមានការលើកឡើងអំពី "អាកប្បកិរិយាផ្លូវភេទ" របស់មនុស្ស ដែលជាឧទាហរណ៍ដោយសេចក្តីថ្លែងការណ៍របស់ Imam Nawawi ថា "ចំណង់អាហារទាំងអស់ធ្វើឱ្យបេះដូងរឹង លើកលែងតែចំណង់ផ្លូវភេទដែលធ្វើឱ្យវាទន់។"[46] មិនមានការលើកឡើងនៅក្នុងគម្ពីរអាល់គួរអានអំពីស្ត្រីថាជាការរួមភេទដ៏គ្រោះថ្នាក់នោះទេ។ ផ្ទុយទៅវិញវាមានគំនិតដែលថាបុរសនិងស្ត្រីគឺដូចគ្នាជាមូលដ្ឋានត្រូវបានបង្កើតឡើងនៃដួងព្រលឹងតែមួយ និងជាអ្នកទទួលបានដង្ហើមដ៏មានភាពអស្ចារ្យទាំងពីរ។(ដូច្នេះ តើសាសនាអ៊ីស្លាមអាចចាត់ទុកភាពជាស្ត្រីថាជាការប្រឆាំងនឹងព្រះជាម្ចាស់ដោយរបៀបណា?) គម្ពីរអាល់គួរអានគឺពោរពេញទៅដោយវាក្យខណ្ឌដែលសង្កត់ធ្ងន់លើសេចក្តីស្រឡាញ់ និងសុខដុមរមនាក្នុងអាពាហ៍ពិពាហ៍ទៅវិញទៅមក។ វាជាចម្ងល់ដែលនាងបានមើលរំលងចំណុចទាំងអស់នេះ (ឧ. គម្ពីរអាល់គួរអាន 30:21)។ ទស្សនៈនៃអាល់គួរអាន អំពីសេចក្តីស្រឡាញ់ទៅវិញទៅមក ការពិចារណា ការអាណិតអាសូរ និងភាពសុខដុមរមនារវាងស្វាមី នឹងប្រពន្ធគឺនៅឆ្ងាយពីទស្សនៈរបស់ Mernissi ដែលលើកឡើងថា៖"បទបញ្ញាតិរបស់អ៊ីស្លាមថ្កោលទោសថាវាជាសត្រូវដ៏សាហាវនៃអរិយធម៌៖ ស្នេហារវាងបុរសនិងស្ត្រីជាទូទៅ, និងរវាងប្តីប្រពន្ធ ជាពិសេស»។[47]

ដើម្បីបញ្ជាក់ពីអ្វីមាននៅក្នុងសាសនាអ៊ីស្លាមមិនមានអ្វីដែលអាក្រក់ ឬការមិនចង់បានអំពីរាងកាយ និងបំណងប្រាថ្នារបស់វានោះឡើយ។ ស្ត្រីពេលសារ៉ាំ ទោះបីជាចូលរួមក្នុងកំហុសនាំឲ្យធ្លាក់ចេញពីឋានសួគ៌ គឺមិនទទួលខុសត្រូវចំពោះការបណ្ដេញចេញពីឋានសួគ៌នោះទេ។(អាដាំគឺជាអ្នកទទួលខុសត្រូវមុនគេ)។ មិនមានអំពើបាបកម្មឡើយចំពោះពួកគេ (ព្រះបានអត់ទោសឱ្យពួកគេ) និងគ្មានភាពមិនបរិសុទ្ធជាប់នឹងនាងនោះឡើយ ដោយសារតែទង្វើនេះដូចនៅក្នុងប្រពៃណីសាសនាផ្សេងទៀត។ សេចក្ដីប៉ងប្រាថ្នាជារបស់ស្ងៃតន ឬនៅក្នុងភាពតានតឹងប្រឆាំងចំពោះគុណធម៌។ វាជាបរិបទដែលកំណត់នូវគុណធម៌ នោះគឺការបំពេញចំណង់ផ្លូវភេទក្នុងអាពាហ៍ពិពាហ៍ត្រូវបានលើកទឹកចិត្ត និងផ្ដល់ផលបុណ្យ។ ការបំពេញចំណង់ផ្លូវភេទនៅខាងក្រៅចំណងអាពាហ៍ពិពាហ៍ត្រូវបានហាមឃាត់ និងត្រូវដាក់ទណ្ឌកម្ម។ រាល់ទង្វើនៅក្នុងជីវិតរបស់អ្នកមានជំនឿរបស់សាសនាអ៊ីអាចជាទង្វើ ឬសកម្មភាពនៃសក្ការៈ ប្រសិនបើវាត្រូវបានធ្វើដោយចេតនាត្រឹមត្រូវ។ ដូច្នេះ ការរួមភេទ មិនមែនជាជាងបង្ហាញនូវការទាស់ទែងប្រឆាំងនឹងអល់ឡោះនោះឡើយ វាគឺជាទង្វើឬសកម្មភាពដែលនាំមកនូវការផ្ដល់នូវផលបុណ្យទាំងបុរស និងស្ត្រីពីព្រះអល់ឡោះជាម្ចាស់។ នៅពេលដែលវាជាទង្វើស្របច្បាប់ ដូច្នេះ ហ៊ីហ្សាបមិនមែនជានិមិត្តសញ្ញានៃសេចក្ដីជំនឿដែល (ជាធម្មតា) ប្រឆាំងនឹងស្ត្រី មានបំណងចង់លុបបំបាត់ភាពជាស្ត្រីឬដកស្ត្រីចេញពីសហគមន៍នៃអ្នកមានជំនឿលើសាសនាអ៊ីស្លាមនោះឡើយ។

## សេចក្ដីសន្និដ្ឋាន

អំណះអំណាងរបស់ Mernissi ដែលថាស្បៃគ្របមុខមិនរាប់បញ្ចូលស្ត្រីនៅក្នុងជំនឿអ៊ីស្លាមរបស់ពួកគេឡើយ ពេលការទទួលហ៊ីហ្សាបនៅកន្លែងសាធារណៈសម្រាប់ស្ត្រី ដូច្នេះហើយចំពោះវាត្រូវបានបដិសេធដោយមតិ និងសកម្មភាពរបស់ស្ត្រីដែលបានចូលរួមនៅក្នុងជំពូកទី3 និងដោយអ្នកសម្ភាសន៍របស់ខ្ញុំនៅក្នុងជំពូកទី2។ ក្នុងភាពការព្រងើយកន្តើយចំពោះសំឡេងរបស់ស្ត្រីដែលគ្របបិទបាំងរាងកាយដោយហ៊ីហ្សាប និងការសន្មត់ពួកគេទៅជាជនរងគ្រោះ Mernissi គឺគ្រាន់តែរៀបរាប់ឡើងវិញនូវទិដ្ឋភាពអាណានិគម និងប្រទេសលោកខាងកើតនៃសង្គម 'ស្ត្រីដែលត្រូវលាក់កំបាំង'នាពេលនោះ។ ពោលមិនមែនជាសង្គមដែលអ៊ីស្លាមជំរុញឲ្យមាននោះឡើយ។

ប្រសិនបើការសន្មត់របស់នាងថា 'នៅក្នុងសាសនាអ៊ីស្លាមមានភាពផ្ទុយគ្នារវាងភាពជាស្ត្រី និងការកំណត់របស់អល់ឡោះ' ដែលតម្រូវឱ្យស្ត្រីត្រូវបានផាត់ចេញ និងដកចេញពោលពីសង្គមអ៊ីស្លាម (ដូច្នេះ ) នៅក្នុងការទទួលហ៊ីហ្សាប ស្បៃគ្របមុខគឺជាការខុសឆ្គងដ៏ធំ គឺខុសដូចដែលខ្ញុំបានបដិសេដវានោះគឺហ៊ីហ្សាបអាចមានអត្ថន័យផ្សេងគ្នាទៀត។

## ជំពូកទី៥
## ទ្រឹស្តីជំនួសនៃស្បៃគ្របមុខ

ចំណុចមួយនៅក្នុងសៀវភៅនេះគឺបង្ហាញអំពីបរិបទសង្គមដ៏មានឥទ្ធិពលលើអត្ថន័យដែលបានកំណត់ចំពោះហ៊ីហ្សាប។ នៅក្នុងជំពូកនេះ ខ្ញុំមានគោលបំណងបង្កើតទ្រឹស្តីវិជ្ជមានអំពីអត្ថន័យ

នៃហ៊ីហ្សាបសម្រាប់វប្បធម៌មូលធននិយមរបស់ពួកលោកខាងលិចនៃសតវត្សរ៍ទី២១។ ខ្ញុំបានអះអាងថាដោយសារមូលធននិយមសង្កត់ធ្ងន់លើរាងកាយ និងលើសម្ភារៈនិយម ការទទួលហ៊ីហ្សាប អាចជាការផ្តល់អំណាច និងបទពិសោធន៍សម្រាប់រំដោះស្ត្រី។ ខ្ញុំវិភាគអំណះអំណាងស្ត្រីនិយមអំពីការមើលរបស់បុរស និងការបញ្ចូលបញ្ហារូបរាងកាយនៅក្នុងសង្គមមូលធននិយមដើម្បីជជែកវែកញែកអំពីហ៊ីហ្សាប វាគឺជាមធ្យោបាយដ៏មានឥទ្ធិពលនិងប្រសិទ្ធភាពមួយដើម្បីទប់ទល់នឹងទិដ្ឋភាពដ៏អាក្រក់របស់វានៅក្នុងសង្គមលោកខាងលិច។ នៅក្នុងផ្នែក C, D និងE ខ្ញុំបានបដិសេធចំពោះការរិះគន់ទូទៅមួយចំនួនអំពីហ៊ីហ្សាប ដែលថាហ៊ីហ្សាបជាសម្លៀកបំពាក់ដែលធ្វើឲ្យប៉ះពាល់ដល់ភាពជាស្ត្រី ធ្វើឱ្យស្ត្រីក្លាយជាវត្ថុនៃចំណង់ផ្លូវភេទ និងការបដិសេធនូវជម្រើសរបស់ពួកគេ។ ជំពូកបិទបញ្ចប់នៃសៀវភៅនេះជាមួយនឹងផ្នែកF ដែលបង្ហាញអំពីហ៊ីហ្សាបដែលវាជាច្រកចូលទៅកាន់ប្រពៃណីនៃការមានជំនឿលើអ៊ីស្លាមដែលជួយអ្នកមានជំនឿប្រតិបត្តិតាមទប់ទល់នឹងឥទ្ធិពលអាក្រក់នៃសង្គមសម្ភារៈនិយមទំនើប។

## A. **ហ៊ីហ្សាប និងការរំដោះខ្លួន និង** B. **ហ៊ីហ្សាប និងការសម្លឹងមើលរបស់បុរស**

សរសេរសម្រាប់សារព័ត៌មានទូទៅ Naheed Mustapha និងSultana Yusufali បង្ហាញថាហ៊ីហ្សាប វាជាការរំដោះចេញពីទិដ្ឋភាពគៀបសង្កត់នៃវប្បធម៌នៃសង្គមមូលធននិយមលោកខាងលិច។ នៅក្នុងការធ្វើដូច្នេះ ពួកគេប្រើការវិភាគស្ត្រីនិយម២ប្រភេទ។[48] វត្ថុបំណងទី១ និងការបញ្ចូលបញ្ហានៃរូបរាងកាយរបស់ស្ត្រីនៃវប្បធម៌មូលធននិយម និងទី២ ទ្រឹស្តីនៃគ្រោះថ្នាក់ដែលធ្វើទៅលើស្ត្រីដោយការលើកកម្ពស់របស់សម្រស់ស្ត្រី។

Orbach, Bordo, Wolf, Ussher, MacKinnon, Dworkin និងអ្នកស្ត្រីនិយមជាច្រើនផ្សេងទៀតបានវិភាគយ៉ាងលម្អិតអំពីទិដ្ឋភាពលើវប្បធម៌លោកខាងលិចរបស់ស្ត្រី។[49] ពួកគេពិនិត្យមើលបញ្ហាវត្ថុបំណងលើរូបរាងកាយស្ត្រី និងការប្រើប្រាស់ទៅក្នុងការផ្សាយពាណិជ្ជកម្ម នូវរូបអាសអាភាស ក្នុងសិល្បៈ ភាពយន្តជាដើម។ ទឡ្ហីករណ៍ចម្បងគឺថារាងកាយរបស់ស្ត្រីត្រូវបានបង្ហាញនៅក្នុងវិធីមួយវាដូចជាដើម្បីបំពេញការសម្លឹងមើលបុរស (ស្រឡាញ់ភេទផ្ទុយគ្នា) និង (ស្រឡាញ់ភេទដូចគ្នា) ជាចំណង់របស់បុរស: ស្ត្រីគឺស្រស់ស្អាត និងរាងកាយរបស់នាងធ្វើឲ្យមានចំណង់ផ្លូវភេទ។ នៅក្នុងសិល្បៈ (ជាពិសេសប្រភេទអាក្រាតកាយរបស់ស្ត្រី) និងរូបអាសអាភាស ស្ត្រីតែងតែនៅស្ងៀម ជារឿយៗអង្គុយសម្រាកហាក់ផ្តល់ជាកម្មសិទ្ធិដល់បុរសដើម្បីយកនាង។[50]នៅក្នុងករណីអំពីរូបភាព/ហ្វីមវីដេអូ 'ការថត' គឺជាការមើលឃើញ ទោះបីជាអ្នកស្ត្រីនិយមមួយចំនួនអះអាងថា អ្វីដែលមើលឃើញនេះមិនមានឥទ្ធិពលនៅក្នុងពិភពពិតដែលវា "កសាងស្ត្រីជារបស់សម្រាប់ [បុរស]សម្រាប់ចំណង់ផ្លូវភេទ។" [51] លើសពីនេះទៅទៀត រាងកាយរបស់ស្ត្រីមិនត្រូវបានកំណត់ឲ្យមានត្រឹមតែក្នុងសិល្បៈនោះទេ ប៉ុន្តែវាមានគ្រប់ទីកន្លែងក្នុងទិដ្ឋភាព គឺជារូបភាព ជាពិសេសនៅក្នុងការផ្សាយពាណិជ្ជកម្ម៖ រាងកាយរបស់ស្ត្រីនៅក្នុងឈុតប៊ីគីនីផ្សព្វផ្សាយទីផ្សាររថយន្ត ("ការទាក់ទាញអតិថិជនបុរសឲ្យទាក់ចិត្ត")។[52] ទំនាក់ទំនង

រវាងផលិតផលដែលលក់ និងរាងកាយបង្ហាញចំណង់ផ្លូវភេទរបស់ស្ត្រីគឺមិនមាន ការលេចរាងកាយរបស់ស្ត្រីគឺនៅទីនោះដើម្បីទាក់ទាញការយកចិត្តទុកដាក់។ វាក៏ធ្វើឱ្យបុរសដែលស្រលាញ់ភេទដូចគ្នាក៏រំភើបដែរ និងពង្រឹងការចង់មើលរាងកាយរបស់ស្ត្រី ប្រៀបដូចគឺជាវត្ថុ ឬរបស់របរ។ ប្រភេទនៃវត្ថុបំណងនេះវាត្រូវបានគេអះអាងថា វាធ្វើឲ្យស្ត្រីបាត់បង់ភាពថ្លៃថ្នូរជាមនុស្ស ប្រែក្លាយស្ត្រីទៅជាវត្ថុរបស់របរ និងប្រឆាំងភាពជាបុគ្គលឯកជនរបស់ពួកគេ។

វាជាផ្នែកមួយដ៏សំខាន់នៃគម្រោងស្ត្រីនិយមដើម្បីផ្លាស់ប្តូរនិងបន្ធូរបន្ថយបញ្ហានេះ។

Mustapha និង Yusufali មើលឃើញថាហ៊ីហ្សាប វាគឺជាផ្លូវចេញមួយអំពីអន្ទាក់ទំនិញ/វត្ថុបំណងផ្សព្វផ្សាយ ជាអ្វីដែលផ្តល់ឱ្យស្ត្រីត្រឡប់មកវិញនូវភាពជាឯកជនបុគ្គលរបស់ពួកគេ។ បន្ថែមលើការសេចក្តីជំនឿអ៊ីស្លាមគឺថា ហ៊ីហ្សាបវាលុបបំបាត់ផលអាក្រក់នៃការសម្លឹងមើលរបស់បុរសដោយការបដិសេធចំពោះស្ត្រី Mustapha និង Yusufali បានអះអាងថា ស្បៃ ឬហ៊ីហ្សាបបានរំដោះចំពោះស្ត្រី ព្រោះវាជួយស្ត្រីឱ្យរួចផុតពីការបំផ្លិចបំផ្លាញ ដោយហ្គេមសម្រស់ ពោលចំពោះពួកគេ។ ហ្គេមសម្រស់គឺជាការព្យាយាមរបស់ស្ត្រីឲ្យខ្លួនពួកគេចូលទៅក្នុងរូបភាពរបស់ស្ត្រីដ៏ស្រស់ស្អាតដែលត្រូវបានគេឃើញនៅជុំវិញពួកគេ។ ក្នុងការស្លៀកសម្លៀកបំពាក់រលុងវែង និងគ្របសក់របស់ពួកគេដោយក្រម៉ា ពួកគេមានអារម្មណ៍ថាត្រូវបានរំដោះចេញពី "ចំណងនៃខ្សែប៉ោលរបស់ឧស្សាហកម្មម៉ូដ និងស្ថាប័នផ្សេងទៀតដែលកេងប្រវ័ញ្ចមនុស្សស្រី" (Yusufali) ការបដិសេធពីភាពស្រស់ស្អាត ពោលភាពខុសឆ្គងនៃល្បែង ពោលការពេញចិត្តនៃហ្គេមសម្រស់នេះពួកគេកំពុងតែឱប ក្រសោប ដែលជានិមិត្តរូបមួយចេញពីបេតិកភណ្ឌអ៊ីស្លាមរបស់ពួកគេ ក្នុងបរិបទផ្សេងទៀតអាចត្រូវបានគេគៀបសង្កត់។ ដូច្នេះ ក្នុងការជ្រើសរើសហ៊ីហ្សាប ពួកគេកំពុងបង្កើតអត្តសញ្ញាណមូស្លីម ជាអត្តសញ្ញាណជនភាគតិចនៅក្នុងសង្គមនៅចំពោះមុខវប្បធម៌និយម លោកខាងលិច)។

សារចំពោះស្ត្រី - អំពីតម្រូវការស្លៀកពាក់ទាន់សម័យ និងឲ្យមានរាងស្លីមស្រស់ស្អាត។ ពួកគេត្រូវប្រើប្រាស់បេតិកភណ្ឌ ពោលសេចក្តីបង្រៀនអ៊ីស្លាមរបស់ពួកគេជាវិធីដើម្បីទប់ទល់ ប្រឆាំង និងទប់ទល់នឹងអំណាចទាំងនេះអំពីរូបភាពនៃសម្រស់ដ៏ស្រស់ស្អាតនោះ។ សម្រាប់អ្នកទាំងនេះ និងគំនិតដូចគ្នាផ្សេងទៀត ស្ត្រីមូស្លីម, ហ៊ីហ្សាបគឺជាវិធានការប្រឆាំងនឹងលោកខាងលិច។ ពួកគេថែមទាំងមានមនសិការខុសឆ្គងផ្ទាល់ខ្លួនរបស់ពួកគេផងដែរចំពោះការលើកឡើងថា៖ "ស្ត្រីនឹងមិនទទួលបានសមភាពជាមួយនឹងសិទ្ធិបង្ហាញសុដន់នៅទីសាធារណៈដូចមនុស្សមួយចំនួនចង់បាន។ " (Mustapha)ដូច្នេះហើយ ការបង្វែរទិសដៅ ឬចង្អុលទៅលើអ្នកស្ត្រីនិយមទាំងនោះដែលនឹងចាត់ទុកការគាំទ្ររបស់ស្ត្រីវ័យក្មេងចំពោះហ៊ីហ្សាបថា ជាមនសិការមិនពិតទៅពិត តែជាក់ស្តែងវាគឺជាការពិត។

## C.**ហ៊ីហ្សាប និងគុណតម្លៃស្ត្រី**

តាមទស្សនៈរបស់អ្នកដែលធ្លាប់បង្ហាញរាងកាយរបស់ស្ត្រី និងបានអះអាងថាត្រឹមត្រូវ និងសម

ស្របនោះគឺ ("ប្រសិនបើអ្នកបានទទួលវាពេលបានមើលនោះ សូមសរសើរ" គឺជាសារទូទៅសម្រាប់ស្ត្រីនៅក្នុងវប្បធម៌លោកខាងលិច) "ការបិទបាំងគ្របដណ្ដប់រាងកាយ វាហាក់ដូចជារារាំងភាពជាស្ត្រី និងភាពស្រស់ស្អាត។ សម្លៀកបំពាក់ដែលមើលទៅគួរឱ្យស្រស់ស្អាតជារឿយៗរបស់ស្ត្រីមូស្លីម ដែលមានការបិទបាំងរាងកាយផ្ដល់ឱ្យរូបរាងដែលភាពជាស្ត្រី និងចំណាប់អារម្មណ៍ភេទរបស់ពួកគេកំពុងត្រូវបានបដិសេធ ពេលមនុស្សមិនចាប់អារម្មណ៍។ នៅក្នុងផ្នែកនេះ ខ្ញុំលើកឡើង៤ចំណុចដើម្បីបដិសេធការសន្មត់ឬគិតថា ហ៊ីហ្សាបវាបំផ្លាញភាពជាស្ត្រីរបស់ស្ត្រី និងបញ្ហាអារម្មណ៍ភេទរបស់ពួកគេ។ ដំបូងឡើយ ស្ត្រីមិនទទួលហ៊ីហ្សាបគ្រប់ពេលវេលានោះទេ។ ទោះបីជាវាត្រូវបានបង្ហាញជាញឹកញាប់ ឬទទួលជាទៀងទាត់តាមរបៀបនេះក៏ដោយក៏ហ៊ីហ្សាប មិនមែនជាសម្លៀកបំពាក់សម្រាប់តែសាធារណៈ ឬឯកជននៅឡើយ៖ វាអាស្រ័យនឹងវត្តមាន ឬអវត្តមានរបស់បុរសដែលអាចរៀបការ ឬមិនអាចរៀបការ ឬសាច់ញាតិរបស់ពួកនាង។ ដូច្នេះនៅពេលដែលស្ត្រីនៅជាមួយគ្នាទាំងអស់ ឬនៅជាមួយស្ត្រី ឬបុរសជាសាច់ញាតិមកពីគ្រួសាររបស់នាង នាងមិនចាំបាច់ទទួលហ៊ីហ្សាបនោះឡើយ។ ដូចគ្នានេះដែរ ពេលនៅខាងក្រៅ ប្រសិនបើមិនមានការសម្លឹងមើលពីបុរសដែលមិនមែនជាសាច់ញាតិទេនោះ ពួកនាងមិនត្រូវការគ្របដណ្ដប់បិទបាំងដោយហ៊ីហ្សាបនោះឡើយ។ ទី២ស្ត្រីត្រូវបានលើកទឹកចិត្តឱ្យស្លៀកពាក់ និងធ្វើឱ្យខ្លួនពួកគេស្រស់ស្អាតរីករាយក្នុងរូបកាយទាក់ទាញរបស់ពួកគេ សម្រាប់ស្វាមីរបស់ពួកគេ។ ទី៣ ដោយសារសង្គមភាគច្រើនមានលក្ខណៈ ឬកម្មវិធីដាច់ដោយឡែកពីគ្នា ដូចជាស្ត្រីចូលរួមជាញឹកញាប់ដោយគ្មានបុរសនៅក្នុងកម្មវិធីដែលមានតែស្ត្រី។ សម្រាប់ឱកាសទាំងនេះ ស្ត្រីជាច្រើនចូលចិត្តតុបតែងខ្លួន និងស្លៀកសម្លៀកបំពាក់ល្អប្រណិត។ ព្រឹត្តិការណ៍ដ៏អស្ចារ្យមួយក្នុងចំណោមព្រឹត្តិការណ៍ ឬកម្មវិធីដ៏អស្ចារ្យបំផុតគឺការងូតទឹកកូនក្រមុំសម្រាប់កូនក្រមុំដោយស្ត្រីស្លៀកពាក់សំលៀកបំពាក់ដ៏ស្រស់ស្អាតបំផុតរបស់ពួកនាង។ នៅក្នុងព្រឹត្តិការណ៍ទាំងនេះ ស្ត្រីចំណាយពេលតុបតែងដៃគ្នាទៅវិញទៅមកជាមួយនឹងលំនាំហិនណា ពេលការគូសរូបផ្កាលើដៃកូនក្រមុំដោយស្លឹកកំផែនដែលបានកិន និងលាយជាមួយទឹកដែលជាប្រពៃណីស្ត្រីមូស្លីម។ ការច្រៀង និងការរាំគឺជារឿងធម្មតា។ ខ្ញុំបានឃើញស្ត្រីវ័យចំណាស់រាំ ទះដៃ និងអង្រួនខ្លួន ជំរុញកូនក្រមុំដែលអៀនខ្មាស់ និងទប់ចិត្តឱ្យអង្រួនខ្លួន និងដងខ្លួនឱ្យកាន់តែមានភាពស្វាហាប់។ និងទី៤ ដើម្បីរំលេចភាពស្រដៀងគ្នារវាងហ៊ីហ្សាប និងយុទ្ធសាស្ត្ររបស់ស្ត្រីផ្សេងទៀត ក្នុងការទប់ទល់នឹងការសម្លឹងរបស់បុរសនៅកន្លែងសាធារណៈ ដូចជាការកោរសក់របស់ពួកគេទាំងអស់ ដែលជារឿងធម្មតាក្នុងចំណោមស្ត្រីនិយមមួយចំនួន។

## D. ហ៊ីហ្សាប បញ្ហាភេទ និងភាពសំខាន់របស់វា

ពួកស្ត្រីនិយម សេរីនិយម ឬសម្ព័ន្ធនិយមទាំង២ បានសន្មត់ថាអាកប្បកិរិយា និងបំណងប្រាថ្នារបស់មនុស្សត្រូវបានបង្កើតឡើងក្នុងសង្គម ដែលមានយុទ្ធសាស្ត្រណាមួយ ដូចជាហ៊ីហ្សាប ដែលហាក់ដូចជាពង្រឹងភាពខុសប្លែកគ្នារបស់បុរសនឹងស្ត្រី ជាប្រពៃណីគឺត្រូវពួកគេសង្ស័យ។

គម្ពីរអាល់គួរអានមិនផ្តល់ការពន្យល់លម្អិតសម្រាប់វាទេ អំពីបទបញ្ញត្តិដែលត្រូវគ្របបិទបាំងរាងកាយ ឬអំពីភាពខុសគ្នានៃសម្លៀកបំពាក់ប្រុស/ស្រី។ ទោះបីយ៉ាងណាក៏ដោយ វាផ្តល់ការពន្យល់ខ្លីៗចំនួន២ ដែលអាចគ្រប់គ្រាន់បានហើយ។ នៅពេលដែលយើងពិនិត្យមើលវាក្យខណ្ឌដូចជានៅក្នុងជំពូកទី24 វាក្យខណ្ឌទី31 "ហើយ កុំឱ្យពួកនាងបង្ហាញសម្រស់របស់នាង លើកលែងតែអ្វីដែលបាន ស្តែងចេញជាធម្មតា(មុខប្រអប់ដៃប្រអប់ជើង)។ ហើយឱ្យពួកនាង យកស្បៃគ្របឱ្យជិតនៅបរិវេណដើមទ្រូង និងករបស់នាង...។" និង ជំពូកទី33 វាក្យខណ្ឌទី 59 ទៅ "ឱណាពី! ចូរអ្នកប្រាប់ទៅកាន់បណ្តាភរិយារបស់អ្នកនិងកូន ស្រីទាំងឡាយរបស់អ្នក និងស្ត្រីរបស់បណ្តាអ្នកមានជំនឿឱ្យបិទបាំង ទៅលើរាងកាយរបស់ពួកនាងដោយស្បៃរបស់ពួកនាង(គឺត្រូវគ្រប ពីក្បាលរហូតដល់ក្រោមទ្រូងនៃរាងកាយ)។ ធ្វើដូច្នោះងាយស្រួល បំផុតដែលពួកនាងនឹងត្រូវគេស្គាល់(ថាជាស្ត្រីមូស្លីមដែលមានសេរីភាព) ហើយពួកនាងក៏មិនអាចត្រូវគេមើលងាយដែរ។ ហើយ អល់ឡោះមហាអភ័យទោស មហាអាណិតស្រឡាញ់។ ខ្ញុំជឿថាអាល់គួរអាន កំពុងជជែកវែកញែកវាជាសាធារណៈថាមានអ្វីមួយអំពីទំនាក់ទំនងបុរស និងស្ត្រីដែលអាចបង្កគ្រោះថ្នាក់ដល់ស្ត្រី និងការស្លៀកពាក់ខាងក្រៅអាចជួរលុងនោះ។ គម្ពីរអាល់គួរអានទុកចោលដោយមិនមានចម្លើយច្បាស់លាស់លំអិតអំពីរបៀប ឬអ្វីដែលសម្លៀកបំពាក់ថាមានម៉ូតអ្វីខ្លះនោះ ប៉ុន្តែនៅពេលដែលអានជាមួយនឹងវាក្យខណ្ឌគម្ពីរអាល់គួរអានមួយនៅក្នុងជំពូកទី24 ដែលបញ្ជាឲ្យ បុរសនិងស្ត្រីឱ្យ "បន្ទាបខ្លួនរបស់ពួកគេ និងរក្សាភាពថ្លៃថ្នូររបស់ពួកគេ" (24: 30-31) ខ្ញុំសន្និដ្ឋានថាគម្ពីរអាល់គួរអាន កំពុងចង្អុលទៅនឹងហេតុការណ៍នៃការសម្លឹងមើលរបស់បុរសដែលបានវិភាគរួចហើយខាងលើ និងបង្ហាញពីភាពសំខាន់នៃការមើលឃើញរបស់បុរសសម្រាប់ចំណង់ភេទរបស់ពួកគេ។″ ទស្សនៈមានគ្រោះថ្នាក់នៅពេលដែលវាត្រូវបានដាក់បញ្ចូល ឬកំណត់ថា'ប្រុស/ស្រីជាអ្នកខ្ពស់ជាង ឬទាបជាងគ្នានៅក្នុងសង្គម និងអាចប្រើដូចធ្លាប់មាននៅសតវត្សរ៍មុនៗ ដើម្បីបដិសេធសិទ្ធិជាមូលដ្ឋានរបស់ស្ត្រីក្នុងជីវិត លើការអប់រំនិងការបោះឆ្នោតជាដើម។ ទោះបីជាយ៉ាងណាក៏ដោយគម្ពីរអាល់គួរអាន មិនមានដាក់ឬកំណត់នូវចំណុចទាំងអស់នេះនោះអំពីភាពខុសគ្នារវាងបុរសនិងស្ត្រី។ ជាការពិតខ្ញុំស្នើឱ្យលើកឡើងពីភាពដូចគ្នាដ៏សំខាន់រវាងបុរសនិងស្ត្រី ដូចជានៅក្នុងវាក្យខណ្ឌនៃជំពូកទី4:វាក្យខណ្ឌទី1៖ "មនុស្សលោក! ចូរពួកអ្នកកោតខ្លាចម្ចាស់របស់ពួកអ្នក ដែលបានបង្កើតពួកអ្នកចេញពីមនុស្សតែមួយគត់(អាដាំ) ហើយ ទ្រង់បានបង្កើតចេញពីគាត់នូវភរិយារបស់គាត់(ហាវ៉ា) ហើយទ្រង់ បានបង្កើតចេញពីអ្នកទាំងពីរនូវបុរសនិងស្ត្រីជាច្រើន។... ″អ្វីដែលគម្ពីរអាល់គួរអានផ្តល់ឱ្យយើងគឺជាការពិពណ៌នាអំពីគ្រោះថ្នាក់ដែលអាចកើតមានសម្រាប់ស្ត្រីនៅទីសាធារណៈ។ ការគ្របដណ្តប់បិទបាំងរាងកាយសម្រាប់ស្ត្រីត្រូវបានអះអាងថាវាជាយុទ្ធសាស្ត្រ ជាងការបញ្ជាក់អំពីអត្តសញ្ញាណស្ត្រី/បុរសដែលចាំបាច់។ បន្ទាប់ពីនោះ ពេលស្ត្រីវ័យចំណាស់ត្រូវបានអនុញ្ញាត ឬលើកលែងខ្លះ "ហើយអ្នកដែលចាស់ជរាក្នុងចំណោមស្ត្រីដែលគ្មានចំណង់ ក្នុងការរៀបអាពាហ៍ពិពាហ៍ទេនោះ គឺគ្មានទោសពៃរ៍អ្វីឡើយសម្រាប់ពួកនាងក្នុងការដោះសំលៀកបំពាក់(ខាងក្រៅ)របស់ពួក នាងដោយពុំមែនក្នុងលក្ខណៈបង្ហាញសម្រស់ទេនោះ។ ហើយការរក្សាភាព ខ្មាស់អៀនគឺប្រសើរសម្រាប់ពួកនាង។ ហើយអល់ឡោះ មហាឮ មហាដឹង។ អាយ៉ះ (24:60) "។ ផ្ទុយពីជំហរពួកសេរីនិយម និងទំនើបនិយម

ដែលសង្ឃឹមថា សង្គមភាវូបនីយកម្មនៅទីបំផុតនឹងលុបបំបាត់ការបៀតបៀនរបស់បុរសចំពោះស្ត្រី គម្ពីរអោល់គួរអានកំពុងណែនាំថានេះគឺជាលក្ខណៈពិសេសមានយូរអង្វែងនៃអត្តិភាពរបស់មនុស្ស។ នេះមិនចាំបាច់មានន័យថាក្នុងជីវសាស្ត្រនោះទេដែលការកំណត់, ក្រូម៉ូសូម XY ដែលមានន័យថាអ្នកបៀតបៀនស្ត្រី៖ បុរសភាគច្រើននឹងមានទំនាក់ទំនងបែបស្នេហាជាមួយស្ត្រីបានយ៉ាងល្អ។ វាជាការដែលសង្គមធ្វើឱ្យអាកប្បកិរិយារបស់បុរសប្រភេទនេះត្រូវបានគេចម្លងជាបន្តបន្ទាប់។

ដូច្នេះ អំណះអំណាងរបស់ខ្ញុំគឺថាហ៊ីហ្ជាបមិនបដិសេធចំពោះបញ្ហាភេទរបស់ស្ត្រីនោះទេ។ មានតែសង្គមនោះទេដែលត្រូវធ្វើឲ្យល្អជាងដោយរក្សាការរួមមេត្រីរបស់បុរស និងស្ត្រីស្ថិតនៅក្នុងការរឹតបន្តឹង និងត្រួតពិនិត្យនៅខាងក្នុង និងខាងក្រៅផ្ទះ និងជាពិសេសនៅទីសាធារណៈ។

## E. **ហ៊ីហ្សាប និងជម្រើស**

ពួកអ្នកប្រាជ្ញសិក្សាពីចលនាបិទបាំងរាងកាយស្ត្រីឡើងវិញរបស់មូស្លីម ក៏ដូចជាពួកលោកខាងលិចជាទូទៅ មានការសង្ស័យចំពោះ 'ជម្រើស' របស់ស្ត្រីដើម្បីគ្របបិទបាំងរាងកាយរបស់ពួកគេ។ ចំពោះរឿងនោះ ពួកគេនៅតែថ្កោលទោសយ៉ាងខ្លាំង ដែលស្ត្រីត្រូវបានបង្ខិតបង្ខំ ឬខួរក្បាលពួកគេត្រូវបានលាងជម្រះយ៉ាងខ្លាំងទៅក្នុងបញ្ហានៃ 'ការជ្រើសរើស' ដើម្បីគ្របបិទបាំងរាងកាយរបស់ពួកគេ។ គំនិតនោះគឺអ្វីមួយដូចជា៖ 'ប្រសិនបើអ្នកបានជ្រើសរើសការបិទបាំងរាងកាយនោះអ្នកមានត្រូវបានសង្គមជឿថាការបិទបាំងរាងកាយគឺជារឿងល្អ។ ទោះបីយ៉ាងណាក៏ដោយប្រសិនបើអ្នកពិតជាដឹងពីចំណាប់អារម្មណ៍របស់អ្នកជាស្ត្រី អ្នកនឹងដឹងថាវាមិនល្អក្នុងការបិទបាំងរាងកាយ ដូច្នេះការសម្រេចចិត្តរបស់អ្នកក្នុងការគ្របបិទបាំងរាងកាយគឺជាការសោកសៅមួយ។ វាបង្ហាញថាអ្នកកំពុងត្រូវបានលាងខួរក្បាល នេះជាទស្សនរបស់ពួកលោកខាងលិច។ ប្រាកដណាស់ នេះជារបៀបខ្ញុំបានគិតមុនពេលខ្ញុំក្លាយជាជនមូស្លីម។

ទំនាក់ទំនងរវាងវប្បធម៌របស់បុគ្គល និងសមត្ថភាពនៃការជ្រើសរើសរបស់ពួកនាងគឺមានភាពស្មុគស្មាញ ព្រោះជម្រើសគឺតែងតែកំណត់នូវវង្វង់រវាងអ្វីដែលវប្បធម៌ត្រូវពិចារណាអាចទទួលយកបាន និងមិនអាចទទួលយកបាន។ សូម្បីតែនៅលោកខាងលិចដូចដែលខ្ញុំបានអះអាងលើកឡើងនៅជំពូកទី៣ ដែលជាកន្លែងលើកឡើងច្រើននូវសេរីភាពដ៏ច្រើនរនៃជម្រើសរបស់មនុស្ស។ សង្គមលោកខាងលិចភាគច្រើននៅតែមានរំពឹងថាស្ត្រីនឹងបិទបាំងដើមទ្រូងរបស់ពួកគេនៅទីសាធារណៈ (លើកលែងតែកន្លែងដាក់លាក់ដូចជាឆ្នេរអាក្រាតកាយ / ជំរុំកំសាន្ត។ គ្មាននរណាម្នាក់អាចប្រកែកបានទេថា ស្ត្រីត្រូវបានបង្ខំដោយវប្បធម៌របស់ពួកគេឱ្យបិទបាំងដើមទ្រូងរបស់ពួកគេដោយសារតែការដាក់ទណ្ឌកម្មប្រឆាំងនឹងការបង្ហាញវា។ ស្ត្រីភាគច្រើនទទួលយកការរឹតបន្តឹង និងមានអារម្មណ៍ថាពួកគេកំពុង 'ជ្រើសរើស' ដើម្បីបិទបាំងដើមទ្រូងរបស់ពួកគេនៅពេលពួកគេស្លៀកពាក់។ វាគឺដូចគ្នាជាមួយនឹងហ៊ីហ្ជាបៈ វាគឺជាសំលៀកបំពាក់ដែលត្រូវបានអនុម័តជ្រើស

រើសតាមវប្បធម៌នៅក្នុងសង្គមមូស្លីមជាច្រើន ដែលស្រ្តីមូស្លីមអាចជ្រើសរើសទទួលយកបាន។ (ទោះបីជាមានសង្គមផ្សេងទៀតដូចជា ហ៊ីហ្សាបនៅ ប្រទេសទួរគីជាឧទាហរណ៍ដ៏ល្បីមួយក្នុង សម័យបច្ចុប្បន្ន។ )ជាការពិតណាស់ អ្វីដែលខ្ញុំកំពុងជជែកគ្នានោះ អនុវត្តន៍ចំពោះតែសង្គម ដែលអនុញ្ញាតឱ្យស្ត្រីមានជម្រើសពិតប្រាកដ មិនមែនកន្លែងដូចជានប្រទេសអ៊ីរ៉ង់ ឬអាហ្វហ្គានី ស្ថានរបស់ពួកតាលីបង់នោះទេ ជាកន្លែងដែលស្ត្រីត្រូវបានរារាំងដោយច្បាប់ពីការបើកបង្ហាញ ឬ ក្នុងអំឡុងពេលនៃចលាចលសង្គមនៅក្នុងពិភពមូស្លីម ដែលជាកន្លែងឬទីតាំងដែលហ៊ីហ្សាប ត្រូវ បានគេមើលឃើញថាជាសញ្ញាសម្គាល់នៃភក្តីភាព និងអំពើហិង្សាគឺជាទង្វើតវ៉ាប្រឆាំងនឹងស្ត្រី ដើម្បីបង្ខំពួកគេឱ្យបិទបាំងរាងកាយទាំងមូល។ អំពើហិង្សាលើស្ត្រីបែបនេះគឺមិនអាចទទួលយក បានទេ។ ខ្ញុំចង់និយាយនៅទីនេះតែពីទំនាក់ទំនងរបស់ហ៊ីហ្សាប ចំពោះជម្រើសក្នុងសង្គម ប៉ុណ្ណោះ ដែលជាកន្លែងដែលមានសេរីភាពពិតប្រាកដក្នុងការទទួលយក ឬមិនទទួលយកហ៊ី ហ្សាប។

## F. ហ៊ីហ្សាប និងសាសនា

ដោយសារតែមានការដាក់ទណ្ឌកម្មសាសនារបស់ខ្លួន និងនៅពេលដែលទទួលហ៊ីហ្សាបស្ត្រី មូស្លីមដឹងដោយខ្លួនឯងសម្រាប់ហេតុផលនៃការគោរពសក្ការៈដូចអ្នកសម្ភាសន៍របស់ខ្ញុំជាច្រើន នាក់ដែលមានលើកឡើងនៅក្នុងជំពូកទី2ហ៊ីហ្សាបដើរតួជាច្រកចូលទៅក្នុងជំនឿមួយនៃអ៊ីស្លាម។ ដូចសាសនារបស់ពិភពលោកធំៗដទៃទៀតដែរ សាសនាអ៊ីស្លាមមានការបង្រៀនបញ្ជាក់អំពីជីវិត បន្ទាប់ស្លាប់ ពោលគឺថ្ងៃបរលោក ហើយអ្នកមានជំនឿត្រូវប្រយ័ត្នមិនត្រូវល្បួងដោយការទាក់ ទាញដោយពាក្យមិនត្រឹមត្រូវឡើយចំពោះរឿងនេះ។គម្ពីរអាល់គួរអានដឹកនាំគំនិតរបស់មនុស្ស ពោលបង្ហាញមនុស្សទៅរកថ្ងៃនៃការកាត់ក្តី ថ្លឹងអំពើល្អអាក្រក់ ដែលជាកន្លែងដែលមនុស្សម្នាក់ៗ នឹងមានអំពើល្អនិងអាក្រក់របស់ខ្លួនដើម្បីយកទៅថ្លឹង។ ការអាណិតអាសូរចំពោះមនុស្សត្រូវបាន រំលឹកជានិច្ចគឺសំខាន់ជាងវការស្លៀកពាក់ ឬហ៊ីហ្សាប់ដែលត្រូវបានលើកឡើងទៅទៀត។ ដូច្នេះ សូម្បីតែការស្លៀកពាក់ ឬទទួលហ៊ីហ្សាប វាគឺជាទង្វើគួរឲ្យគោរព វាជាកម្រិតបឋមបណ្ណោះ។ ហា ទីសពីស្តហេសមូស្លីមបានលើកឡើងថា: "អល់ឡោះមិនមើលរូបរាងរបស់អ្នក ឬទ្រព្យសម្បត្តិ របស់អ្នកទេ ប៉ុន្តែទ្រង់មើលលើចិត្ត និងទង្វើរបស់អ្នក" (លេខ ២៥៦៤)"។

វិធីមួយទៀតហ៊ីហ្សាប នៅពេលដែលត្រូវបានអនុម័តជាបញ្ញាតិនៅក្នុងសាសនាអ៊ីស្លាមវាអាច ប្រឆាំងទប់ទល់នឹងវប្បធម៌សម្ភារៈនិយមរបស់មូលធននិយមលោកខាងលិច។ គម្ពីរ អាល់គួរអាន ជាសារបានបង្ហាញអំពីភាពល្អឥតខ្ចោះនៃរាងកាយមនុស្ស។ ការមិនសប្បាយចិត្ត និងការមិន ពេញចិត្តនៃរាងកាយរបស់មនុស្សកំពុងឈានក្លាយរជំងឺនៅលោកខាងលិច ប៉ុន្តែនេះអាចកើត មានទៅបានតែនៅក្នុងវប្បធម៌ដែលមានមានជំនឿជឿថាព្រះបង្កើតឲ្យមានអ្វីៗទាំងអស់ រួមទាំង របស់មួយ ឬរូបរាងរាងកាយមួយ។ វាប្រហែលអាចថារាងកាយគឺជាកន្លែងមួយ មានការប្រព្រឹត្ត អនុវត្តន៍ និងការបង្កើតវប្បធម៌បែបនោះ គឺមិនមានទេ វត្ថុនោះជា 'រូបកាយជីវសាស្ត្រ' ពោលពួក លោកខាងលិចមិនមានជំនឿឡើយចំពោះរឿងនោះ។[53] ទោះបីជាយ៉ាងណាក៏ដោយ វាក៏ជាការ ពិតដែរ។ មនុស្សម្នាក់មិនអាចផ្លាស់ប្តូររចនាសម្ព័ន្ធរាងកាយរបស់មនុស្សម្នាក់ច្រើនពេក ដោយ

គ្មានការវះកាត់នោះឡើយ។ ទោះបីជាមនុស្សម្នាក់អាចតមអាហារ និងហាត់ប្រាណក៏ដោយ ប្រសិនបើមនុស្សម្នាក់ស្ថិតនៅក្នុងដែនកំណត់ដែលមានសុខភាពល្អ (នោះក៏អាចមានជំងឺដដែល) និងមានតែការច្របូកច្របល់ច្រើនដដែលដែលត្រូវព្យាបាលឬដោះស្រាយ។ សាររបស់គម្ពីរអាល់គួរអាន គឺឲ្យយើងរីករាយ និងពេញចិត្តជាមួយនឹងរូបកាយរបស់មនុស្សើងសម្នាក់ៗ ពីព្រោះព្រះជាម្ចាស់បានបង្កើតរូបរាងរបស់យើង៖ "ទ្រង់គឺជាអ្នកដែលបង្កើតរូបអ្នកនៅក្នុងស្បូន ដូចដែលទ្រង់សព្វព្រះហឫទ័យ" (3:6) ហើយទ្រង់បានបង្កើតយើង"នៅក្នុងទម្រង់ដ៏ល្អបំផុត" (95: 4) ព្យាការីលោកធ្លាប់ទូន្មានមនុស្សឱ្យមានសុខភាពល្អ ដោយត្រូវទទួលទាន និងហាត់ប្រាណក្នុងកម្រិតមធ្យមល្មម។

ដូច្នេះ អ៊ីស្លាមដើរតួជាអ្នកប្រឆាំងទៅនឹងសង្គមសម្ភារៈនិយមនៃពួកមូលធននិយមលោកខាងលិច។ ការទទួលយកហ៊ីហ្សាបស្ត្រីមូស្លីមបានចូលទៅក្នុងជំនឿយ៉ាងជ្រាលជ្រៅនៃប្រពៃណីដែលផ្តល់ជាប្រភពនូវភាពវិជ្ជមានដើម្បីប្រឆាំងនឹងផលប៉ះពាល់នៃសង្គមសម្ភារៈនិយម។

### G..**សេចក្តីសន្និដ្ឋាន**

អំណះអំណាងនេះកាន់តែឧត្តុងឧត្តមក្នុងជំពូកនេះគឺថាហ៊ីហ្សាប វាជាសកម្មភាពជាឧបករណ៍ផ្តល់អំណាចនៃការតស៊ូប្រឆាំងនឹងល្បែងសម្រស់ស្ត្រី នៃវប្បធម៌មូលធននិយមនៃសតវត្សរ៍ទី21 ដែលមានមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើការគោរពតម្លៃខ្លួនឯង និងសុខភាពរាងកាយរបស់ស្ត្រី។ ហ៊ីហ្សាបក៏ជាសម្លៀកបំពាក់ដែលមានការគាំទ្រខាងសាសនា និងតំណភ្ជាប់របស់វាទៅនឹងទំនៀមទម្លាប់ជំនឿដែលលើកកំពស់ការគោរពខ្លួនឯង សាសនាផ្តល់ឱ្យអ្នកទទូវានូវច្រកចូលដោយរំឭកមនុស្សថាតម្លៃរបស់ពួកគេមិនផ្អែកលើរូបរាងកាយនោះទេ ប៉ុន្តែអាស្រ័យលើភាពស្មោះត្រង់ និងទង្វើរបស់ពួកគេ។ តាមទស្សនៈនេះ ហ៊ីហ្សាប គឺជានិមិត្តសញ្ញានៃសាសនាមួយដែលចាត់ទុកស្ត្រីជាមនុស្ស មិនមែនវត្ថុសម្រាប់មប្រើផ្លូវភេទនោះឡើយ។ នេះគឺជាការសន្និដ្ឋានផ្ទុយស្រឡះចំពោះពួកស្ត្រីនិយមទូទៅរបស់លោកខាងលិច ដែលមានគំនិតដែលថាហ៊ីហ្សាប គឺជានិមិត្តសញ្ញា ដែលសាសនាអ៊ីស្លាមចាត់ទុកស្ត្រីជាវត្ថុបម្រើផ្លូវភេទដែលពួកនាងត្រូវតែបិទបាំងព្រោះពួកនាងត្រូវបានគេគិតថា ត្រូវបានកាត់បន្ថយភាជា "ស្ត្រី" ដែលមានសារៈសំខាន់ជាគុណលក្ខណៈគឺជាភេទរបស់ពួកនាងដែលគំរាមកំហែងដល់សណ្តាប់ធ្នាប់សង្គម ពោលដែលទាំងនេះជាចោទប្រកាន់របស់ពួកគេលើអ៊ីស្លាម។

## **សេចក្តីសន្និដ្ឋាន**

សៀវភៅរបស់ខ្ញុំបានចាប់ផ្តើមជាមួយនឹងការព្យាយាមប្រឹងប្រែងរបស់ខ្ញុំ ដើម្បីយល់ពីមូលហេតុរបស់សង្គមសេរីនិយមដែលគិតអំពីរបៀបដែលបុគ្គលបន្តនូវទង្វើល្អ ប្រតិកម្មនឹងទង្វើ ដែលមិនល្អ។ ចំពោះខ្ញុំដែលក្លាយជាអ្នកមូស្លីម និងការទទួលយកការស្លៀកពាក់ដោយមានហ៊ីហ្សាប។ ដំណើរស្វែងយល់របស់ខ្ញុំ បានឲ្យខ្ញុំធ្វើដំណើរត្រឡប់ទៅសម័យអាណានិគម នៅពេលដែលជន

ជាតិអឺរ៉ុបបានជួបប្រទះឬឃើញជាលើកដំបូងនូវហ៊ីហ្សាប ទៅសម័យមុន ដែលជាកន្លែងដែលបន្ទាប់ពីមានការបោះបង់ចោលហ៊ីហ្សាប ស្ត្រីមូស្លីមខ្លះបានស្លៀកពាក់ដោយទទួលវាម្តងទៀត។ ខ្ញុំបានបង្ហាញពីសំឡេងរបស់ស្ត្រីមូស្លីមមួយចំនួនដែលរស់នៅក្នុងទីក្រុងតូរ៉ុនតូ ដែលស្លៀកពាក់គ្របដណ្តប់បិទបាំងរាងកាយរបស់ពួកគេ និងបានធ្វើការវិភាគពីសំឡេងដែលដាក់សម្ពាធសង្កត់ទៅលើសំឡេងរបស់ស្ត្រីដែលប្រឆាំងនឹងហ៊ីហ្សាប។ ជាចុងក្រោយ ខ្ញុំបានព្យាយាមបង្ហាញភាពវិជ្ជមានអំពីទស្សនៈយល់ឃើញអំពីហ៊ីហ្សាបសម្រាប់វប្បធម៌មូលធននិយមនាគ្រាដំបូងនៃសតវត្សរ៍ទី20។

ហ៊ីហ្សាបវាគឺជាទស្សនៈមួយអំពីសម្លៀកបំពាក់បុរស និងស្ត្រីជាក្រមសីលធម៌សម្រាប់ទំនាក់ទំនងបុរសនឹងស្ត្រី។ ទោះបីយ៉ាងណាក៏ដោយវាគឺជាបំណែកនៃក្រណាត់ដែលគ្របបិទបាំងលើរាងកាយរបស់ស្ត្រីដែលមានកម្រិតវែងខ្លីខុសៗគ្នាផងដែរ។ គេបានស្គាល់ថាវាជាហ៊ីហ្សាប នោះគឺជាការផ្តោតអារម្មណ៍នៃអរិភាពនៅលោកខាងលិច ដូចជាក៏ដូចជានៅកន្លែងនៃការតស៊ូដ៏ជូរចត់នៅក្នុងពិភពមូស្លីម។ នៅក្នុងប្រទេសទួរគី និងទុយនីស៊ី ច្បាប់ហាមប្រាមអំពីហ៊ីហ្សាបត្រូវបានអនុម័តនៅក្នុងនាម "សម័យទំនើប" ដែលជាសម័យទំនើបដោយផ្អែកលើបូព៌ានិយម ពេលជាសម័យដែលប្រទេសពិភពមូស្លិមជាពិសេសទួរគី ទុយនេស៊ីទទួលឥទ្ធិពលអរិយធម៌លោកខាងលិចដ៏ខ្លាំងក្លាលែងខ្វល់នឹងច្បាប់អ៊ីស្លាម និងដោយមើលឃើញថាសាសនាអ៊ីស្លាមគឺជាការថយក្រោយ ប្រឆាំងនឹងអរិយធម៌ទំនើប មានភាពព្រៃផ្សៃ និងសង្កត់សង្កិនលើស្ត្រី។ ត្រង់ចំណុចនេះគឺលោកខាងលិចមានគំនិតជាទូទៅថាហ៊ីហ្សាបគឺជាការគៀបសង្កត់ និងមានការប៉ុនប៉ងលុបបំបាត់ហ៊ីហ្សាបពីពិភពលោកមូស្លីមនាសម័យកាលនោះ។

រហូតមកដល់ពេលនេះ គំរូស្ត្រីនិយមរបស់លោកខាងលិចមិនទាន់បានទទួលយកទាំងស្រុងនៅលើពិភពលោកនោះឡើយ។ រីឯបទពិសោធន៍វិជ្ជមានរបស់ស្ត្រីជាមួយនឹងការទទួលហ៊ីហ្សាបក៏មិនមានទាំងស្រុងផងដែរ។ ពិភពលោកបានទទួលយកភាពចម្រុះទាក់ទងនឹងការគ្របដណ្តប់វាគឺជាបញ្ញាតិនៃបូព៌ានិយម ដែលពួកអ្នក បិទបាំងរាងកាយ និងមិនគ្របបិទបាំងដោយហ៊ីហ្សាប។ ស្ត្រីនិយមលោកខាងលិចគួរតែគោរព ឲ្យតម្លៃទៅវិញ ដែលស្ត្រីមូស្លីមដែលគ្របបិទបាំងរាងកាយពួកគេ មិនធ្វើការឆ្លើយតបដោយសម្តី ជាជាងសកម្មភាពស្លៀកពាក់ដោយហ៊ីហ្សាបជាទៀងទាត់របស់ពួកគេ។ពួកស្ត្រីនិយមលោកខាងលិច ភ្លេចអំពីការគៀបសង្កត់ស្ត្រីដែលកំពុងប្រឈមមុខនឹងវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ ដោយចាត់ទុកស្ត្រីមូស្លីមជាស្ត្រី គឺជាក្រុមដែលនៅសេសសល់ក្នុងពិភពលោកដែលទទួលរងការគៀបសង្កត់ ពោលលដោយភ្លេចសង្គមខ្លួនឯង។ ដូច្នេះតួនាទីនយោបាយអំណាចនៅក្នុងការបន្តនៃការគាបសង្កត់លើស្ត្រីមូស្លីម ដែលទទួលហ៊ីហ្សាបមិនអាចមើលរំលងបានឡើយ។ នៅក្នុងវិធីជាច្រើន សុន្ទរកថាប្រឆាំងហ៊ីហ្សាបត្រូវបានផ្សារភ្ជាប់ទៅនឹងគម្រោងនៃអនុត្តរភាពលោកខាងលិច ទោះបីជាអនុត្តរភាពនោះត្រូវបានគេមើលឃើញថាវាមានជាធម្មជាតិ និងមិនមែនក៏ដោយ ដែលជាលទ្ធផលនៃគោលនយោបាយការបរទេសជាក់លាក់គ្រប់បែបយ៉ាងរបស់ពួកគេ។

អ្នកខ្លះបានតវ៉ាដោយត្រឹមត្រូវ នៅក្នុងសង្គមមូស្លីមខ្លះ ស្ត្រីបានរស់នៅដាច់ដោយឡែក ពួកគេត្រូវបានបង្ខំឱ្យគ្របដណ្តប់បិទបាំងរាងកាយ។ ហ៊ីហ្សាបគឺជាផ្នែកមួយនៃការកំណត់ភាពជាស្ត្រីនូវសក្តានុពល បដិសេធពួកគេមិនឲ្យទទួលបានការអប់រំ មានការងារនៅខាងក្រៅផ្ទះ និងមានសិទ្ធក្នុងការបោះឆ្នោត ពេលប្រទេសមូស្លីមខ្លះប្រកាន់ជ្រុលលើសពីកម្រិតអ៊ីស្លាមបានដាក់បញ្ញត្តិ។ វាមិនចម្លែកទេដែលដូចជា Mernissi មានមនុស្សជាច្រើន ដូចជាស្ត្រីមូស្លីមធ្វើយុទ្ធនាការប្រឆាំងនឹងការហ៊ីហ្សាប និងអបអរចំពោះការលុបបំបាត់ហ៊ីហ្សាប។ ចលនាគ្របដណ្តប់បិទបាំងរាងកាយដោយហ៊ីហ្សាបជាថ្មីគឺជាវ៉ាឌីកាល់ប្រឈមនឹងការគៀបសង្កត់របស់លោកខាងលិច ទាំងទំនៀមទម្លាប់ប្រពៃណីអ៊ីស្លាមមួយចំនួនផងដែរ។ ការវិលត្រឡប់ទៅកាន់អាល់គួរអាន និងស៊ុនណះដែលមានការលើកឡើងជាច្រើន គឺជាដំណោះស្រាយ។ មានអ្នកទាំងនោះផ្សេងទៀត រួមទាំងខ្លួនខ្ញុំផងដែរ ដែលមើលឃើញថាគម្ពីរអាល់គួរអាន និង ស៊ុនណះដែលជាព្យាការី និងសហគមន៍មូស្លីមជាសម័យដើមដំបូងដែលបង្ហាញពីសមភាព និងយុត្តិធម៌រវាងស្ត្រី និងបុរស ប៉ុន្តែរបៀបនៃជីវិតបុរសស្ត្រីដ៏ត្រឹមត្រូវនេះត្រូវគេបង្ខូចតម្លៃរបស់វា ដោយនៅក្នុងការទទួលស្គាល់វប្បធម៌ក្នុងរយៈពេល1,400 ឆ្នាំចុងក្រោយនេះ។ ជនម៉ូស្លីមទាំងបុរស និងស្ត្រីដែលយល់ឃើញទាំងនេះពេលដែលទទួលឥទ្ធិពលពួកអាណានិគមកំពុងអះអាងថា ហ៊ីហ្សាប (គួរតែ) ត្រូវបានរំដោះចេញពីប្រពៃណីដែលសង្កត់សង្កិនពីអតីតកាល ដូចជាភាពឯការបស់ស្ត្រី និងការគៀបសង្កត់ទាំងនោះបានធ្វើឲ្យស្ត្រីមិនបានចូលរួមយ៉ាងត្រឹមត្រូវរបស់ពួកគេក្នុងកិច្ចការរបស់សហគមន៍ ពួកគេទាមទារឲ្យមានការអប់រំ មានការងារ និងមានសកម្មភាពធ្វើនយោបាយជាដើម ពេលទាំងនេះជាអ្វីដែលមានស្រាប់នៅសម័យកាលរបស់ព្យាការី។

ភាពខុសគ្នានៃគំនិតទាំងនេះលើហ៊ីហ្សាប មិនគួរត្រូវបានអនុញ្ញាតឱ្យយកឈ្នះលើសហគមន៍មូស្លីមសព្វថ្ងៃនេះទេ។ ភាពខុសគ្នានៃគំនិត វាគឺជាលក្ខណៈសម្គាល់នៃគ្រាដំបូងនៃសហគមន៍មូស្លីមនៃសម័យកាលដើម។ ហ៊ីហ្សាប គេច្រើនតែឈ្លក់វង្វេងដោយគិតថា ហាក់ដូចជារឿងដែលសម្គាល់លើស្ត្រីម្នាក់ជាមូស្លីមឬក៏អត់។ អ្វីដែលគេបំភ្លេចចោលនោះគឺថា វាគឺជាសាហាហ្ទះ(ការប្រកាសអះអាង និងមានជំនឿថា គ្មានអ្នកណាដែលត្រូវគោរពសក្ការៈ លើកលែងតែព្រះអល់ឡោះជាម្ចាស់តែមួយអង្គគត់ និងព្យាការីមហាំម៉ាត់គឺជារ៉សូលអ្នកនាំសាររបស់ទ្រង់) នេះជាអ្វីដែលធ្វើឱ្យមនុស្សម្នាក់ក្លាយជាមូស្លីម ឬអ្នកកាន់សាសនាអ៊ីស្លាម បន្ទាប់ពីនោះ សកម្មភាពសំខាន់បំផុតគឺការថ្វាយបង្គំសឡាតមួយថ្ងៃ៥ដងឲ្យទាន់ពេលវេលា។ លំអានព្យាការីមហាំម៉ាត់រំឭកយើងថា ស្ត្រីមូស្លីមដែលប្រព្រឹត្តនឹងត្រូវទារុណកម្មនៅជីវិតបន្ទាប់ពីស្លាប់ ពេលនៅថ្ងៃបរលោក ប្រសិនបើពួកគេនិយាយដើមគេក្នុងជីវិតនេះ។ វិសាលភាពនៃទង្វើរបស់មនុស្សមិនមែនជាការងាររបស់យើងដែលត្រូវព្រួយបារម្ភនោះឡើយ។ អ្វីដែលគួរបារម្ភត្រូវគិតជាងការស្លៀកពាក់របស់ស្ត្រីម្នាក់ទៀតគឺអាកប្បកិរិយា និងទង្វើរបស់យើង។ ដូច្នេះ សកម្មភាពនៃការ "អភិរក្ស" វិសាលភាពដែលត្រូវប្រុងប្រយ័ត្នចំពោះភាពក្រអឺតក្រទម និងការបរិហារអ្នកដែលមិនចង់ពាក់ហ៊ីហ្សាប ក៏ដូចជាផ្នែក "នៃវឌ្ឍនភាព" របស់វា។ ការបរិហារចំពោះអ្នកដែលចង់ពាក់ហ៊ីយ៉ាប ឬនីកប

ពេលប្រភេទហ៊ីហ្សាបមួយប្រភេទទៀត។លើសពីនេះទៀត សេរីភាពនៃសតិសម្បជញ្ញៈរបស់ភាគីទាំងសងខាងគួរតែមានរក្សាឲ្យបាន។ចាប់តាំងពីខ្ញុំធ្វើការស្រាវជ្រាវដំបូង វាមានការកើនឡើងនៃការលើកឡើងនៅក្នុងចំណោមអ្នកកាន់សាសនាអ៊ីស្លាមពីអំណះអំណាងដែលថា ហ៊ីហ្សាប មិនមែនជាតម្រូវការនៃការស្លៀកពាក់បែបសាសនានោះទេ ប៉ុន្តែគ្រាន់តែជាវប្បធម៌។ខ្ញុំបានស៊ើបអង្កេតរឿងនេះ ខណៈដែលខ្ញុំកំពុងធ្វើការសម្រេចចិត្តរបស់ខ្ញុំដើម្បីផ្លាស់ប្តូរចូលកាន់សាសនាអ៊ីស្លាមហើយបានសន្និដ្ឋានចំពោះអំណះអំណាងរបស់ពួកគេគឺផ្អែកលើភស្តុតាងទន់ខ្សោយ និងមិនស៊ីសង្វាក់គ្នា។ ខ្ញុំមានការបារម្ភថាការកើនឡើងនៃនិន្នាការ"ហ៊ីហ្សាបនេះដែលលើកឡើងថាមិនមែនជាកាតព្វកិច្ចនៅក្នុងសាសនាអ៊ីស្លាមទេ" ព្រោះវាត្រូវបានគាំទ្រដោយភាគច្រើននៅលោកខាងលិចដោយភាពរីករាយនៃសេរីភាពលែងខ្លួន មានតែស្ត្រីមូស្លីមប៉ុណ្ណោះដែលចង់ទទូល ឬស្លៀកពាក់ហ៊ីហ្សាបនោះ។ សំឡេងរបស់ពួកគេឥឡូវត្រូវបានរុញទៅគែមនៅខាងចុង តាមរយៈការផ្សព្វផ្សាយវប្បធម៌លោកខាងលិច និងអ្នកមូស្លីមដែលចម្រើននិយមលោកខាងលិច។ មិនមែនស្ត្រីទាំងអស់ដែលត្រូវបានសម្ភាសន៍សម្រាប់ទស្សនៈអំពីការគិតឡើងវិញទៅលើស្ត្រីមូស្លីម និងហ៊ីហ្សាប ឬចង់ទទូលគ្របក្បាលនោះទេ ប៉ុន្តែមានមនុស្សជាច្រើនបានធ្វើ អនុវត្តន៍វា និងចំពោះក្របខ័ណ្ឌទាំងមូលនៃសៀវភៅនេះ គឺគាំទ្រដល់ទស្សនៈដែលថាហ៊ីហ្សាបគឺជាសំលៀកបំពាក់ដែលផ្សើមានមានសណ្តាប់ធ្នាប់នៅសាសនា ដែលមិនមែនជាការគៀបសង្កត់ និងវាជាផ្នែកមួយនៃសាសនាអ៊ីស្លាមដែលផ្តល់សេចក្តីថ្លៃថ្នូរដល់ស្ត្រីមូស្លីម។

*ការគិតឡើងវិញអំពីស្ត្រីមូស្លីម និងស្បៃមុខ ឬហ៊ីហ្សាប* ដែលជាចំណងជើងនៃសៀវភៅមួយក្បាលនេះ យើងខ្ញុំសង្ឃឹមថា វានឹងបម្រើជាទស្សនទានសម្រាប់ការពិភាក្សានានាអំពីវា។ សៀវភៅរបស់ខ្ញុំនេះ គឺមានគោលបំណងដើម្បីបង្ហាញរឿងមួយផ្សេងទៀតអំពីស្បៃមុខ ឬហ៊ីហ្សាបនេះ។ រឿងរ៉ាវទាំងអស់នោះពេលនៅក្នុងសៀវភៅ មានដូចជារូបខ្ញុំបានស្វែងយល់តម្លៃសន្តិភាព និងសេចក្តីរីករាយក្នុងសាសនាអីស្លាមអំពីហ៊ីហ្សាប។ ចំពោះអ្នកណាដែលមិនជឿលើអ៊ីស្លាម នឹងជឿថាហ៊ីហ្សាបគឺសង្កត់សង្កិនពួកគេ។ សៀវភៅរបស់ខ្ញុំគឺមានគោលបំណងបើកបន្ទាត់នៃការប្រាស្រ័យទាក់ទងជាមួយអ្នកដែលមានឆន្ទៈក្នុងការស្តាប់ដើម្បីស្វែងយល់។ វាក៏បានស្នើសុំឱ្យស្ត្រីមូស្លីមដែលចូលចិត្តទទូលហ៊ីហ្សាបត្រូវប្រព្រឹត្តដោយការគោរព ត្រង់ត្រាប់ស្តាប់ដោយសុភាពរាបសារ និងឆ្លើយតប ពេលនឹងការចោទប្រកាន់ជាមួយនៅក្នុងស្មារតីនៃសុច្ឆន្ទៈ។ យើងប្រហែលអាចជាយល់ព្រមចំពោះការមិនយល់ស្របបញ្ហាមួយចំនួន ប៉ុន្តែទោះបីជាយ៉ាងហោចណាស់ក៏ដោយ យើងគួរតែអាចធ្វើបានពេលចំពោះការស្វែងយល់ពីគ្នា និងនៅតែជាដៃគូនៅសកលលោកនេះជាមួយគ្នា។

# អ្នកនិពន្ធ

KATHERINE BULLOCK បានបញ្ចប់ថ្នាក់បណ្ឌិតរបស់លោកស្រីក្នុងជំនាញវិទ្យាសាស្ត្រនយោបាយនៅឯសាកលវិទ្យាល័យតូរ៉ុនតូក្នុងឆ្នាំ១៩៩៩។ លោកស្រីបានបង្រៀន និងធ្វើជាសាស្ត្រាចារ្យនៅរដ្ឋកាលីហ្វ័រញ៉ា និងទីក្រុងតូរ៉ុនតូ ស្តីពីអរិយធម៌ និងនយោបាយអ៊ីស្លាម។ ការងារភាគច្រើនបំផុតរបស់លោកស្រីគឺនៅសាកលវិទ្យាល័យតូរ៉ុនតូ ដែលជាកន្លែងដែលនាងបានបង្រៀនវគ្គមួយដែលមានប្រធានបទឈ្មោះថា "នយោបាយនៃសាសនាអ៊ីស្លាម" តាំងពីឆ្នាំ២០០២។

បច្ចុប្បន្នលោកស្រីគឺជាប្រធានវិទ្យាស្ថាន Tessellate ដែលជាវិទ្យាស្ថានស្រាវជ្រាវមិនរកប្រាក់ចំណេញ និងស្ថាប័នក្រុមហ៊ុនបោះពុម្ពដែលទើបបានបានបង្កើតឡើងថ្មីផងដែរ។លោកស្រីជានិពន្ធនាយកនៃ American Journal of Islamic Social (AJISS) ពីឆ្នាំ ២០០៣-២០០៨ និងជាអនុប្រធាននៃសមាគមអ្នកវិទ្យាសាស្ត្រសង្គមមូស្លីម (អាមេរិកខាងជើង) ពីឆ្នាំ២០០៦-២០០៩។

ស្នាដៃនៃការបោះពុម្ពផ្សាយរបស់លោកស្រីរួមមានៈ *សកម្មជនស្ត្រីមូស្លីមនៅអាមេរិកខាងជើង៖ ការនិយាយសម្រាប់ខ្លួនយើង និងការគិតឡើងវិញអំពីស្ត្រីមូស្លីម និងស្បៃគ្របមុខៈ ការប្រឈមមុខនឹងប្រវត្តិសាស្ត្រ និងសម័យទំនើប* ដែលត្រូវបានបកប្រែជាភាសាបារាំង និងភាសាទួរគី។

លោកស្រីជាសកម្មជនសហគមន៍ និងជាគ្រូបង្រៀនជាទៀងទាត់សម្រាប់ទាំងក្រុមអ្នកមូស្លីម និងមិនមែនមូស្លីម។ លោកស្រីមានដើមកំណើតមកពីប្រទេសអូស្ត្រាលី និងបានរស់នៅក្នុងប្រទេសកាណាដាជាមួយស្វាមី និងកូនៗ។ លោកស្រីបានទទួលយកអ៊ីស្លាមនៅឆ្នាំ១៩៩៤ ។

# កំណត់សម្គាល់

[1] *The Complete Letters of Lady Mary Wortley Montagu*, quoted in Leila Ahmed, *Women and Gender in Islam: Historical Roots of a Modern Debate* (New Haven: Yale University Press, 1992), p.150.
[2] Orientalism became a field of knowledge, or paradigm, for understanding the Middle East and Islam that pretended to objectivity (impartiality), but that was actually based on the guiding assumption of inherent Oriental inferiority. Edward Said, *Orientalism* (1979, 2nd Ed., New York: Vintage Books, 1994), p.209.
[3] Ahmed, *Women and Gender in Islam*, p.128.
[4] Ibid., pp.129–30.
[5] Ibid., p.145.
[6] Ibid., p.129.
[7] Timothy Mitchell, *Colonising Egypt* (Berkeley: Uni. of California Press,1988), pp.12–13, *passim*.
[8] Ibid.,
pp.19–20.
[9] Ahmed, *Women and Gender in Islam*, p.104.
[10] The Quebec issue followed on from French expulsions of girls in hijab in 1989. Naturally there are connections between French and Quebec culture.
[11] Canadian Broadcasting Commission, Prime Time News, July, 1995.
[12] Jeffery Simpson, "The Current Objections to Muslim Clothing are Simply Wrongheaded," *Globe and Mail* (Toronto, Canada), December 28, 1994, p.A16.
[13] Mona LeBlanc, Letters to the Editor, *Globe and Mail*, Wednesday, January 4, 1995.
[14] I say "other people" because most of the interviewees, even though they observed the five pillars of Islam, did not consider themselves "religious." They felt they would have to do more prayers, or read more Qur'an, to be truly religious.
[15] Yvonne Yazbeck Haddad, "Arab Muslims and Islamic Institutions in America: Adaptation and Reform," in *Arabs in the New World: Studies on Arab-American Communities*, eds. Sameer Y. Abraham and Nabeel Abraham (Detroit: Wayne State University Centre for Urban Studies, 1983), p.75.
[16] Azza M. Karam, *Women, Islamisms and the State: Contemporary Feminisms in Egypt* (London: Macmillan, 1998), p.133.
[17] Ibid., p.139.
[18] For Algeria, see Frantz Fanon, *A Dying Colonialism*. Trans. Haakon Chevalier (New York: Grove Press, 1967). French edition, 1959, pp.61–62, *passim*. For Iran, see Azar Tabari, "Islam and the Struggle for Emancipation of Iranian Women," in *In the Shadow of Islam: The Women's Movement in Iran*, eds. Azar Tabari and Nahid Yeganeh (London: Zed Press, 1982), p.13.
[19] Sherifa Zuhur, *Revealing Reveiling: Islamist Gender Ideology in Contemporary Egypt* (New York: State University of New York Press, 1992), p.108.

[20] John Williams, "A Return to the Veil in Egypt," *Middle East Review*, 11, 3, (1979), p.50.
[21] Zuhur, *Revealing Reveiling*, p.2. Zuhur found this ideal contradicted by the Yves St. Laurent line of headscarves available for purchase. See also Leila Hessini, "Wearing the *Hijab* in Contemporary Morocco: Choice and Identity," in *Reconstructing Gender in the Middle East: Tradition, Identity, and Power*, eds. Fatma Müge Göçek and Shiva Balaghi (New York: Columbia University Press, 1994), p.50.
[22] Williams, "A Return to the Veil," p.54.
[23] Homa Hoodfar, "Return to the Veil: Personal Strategy and Public Participation in Egypt," in *Working Women: International Perspectives on Labour and Gender Relations*, eds. Nanneke Redclift and M. Thea Sinclair (London: Routledge, 1991), pp.110–111; Arlene Elowe Macleod, *Accommodating Protest: Working Women and the New Veiling in Cairo* (New York: Columbia University Press, 1991), pp.114, 121.
[24] Helen Watson, "Women and the Veil: Personal Responses to Global Process," in *Islam, Globalization and Postmodernity*, eds. Akbar S. Ahmed and Hastings Donnan (London: Routledge, 1994), p.148. Nadia is the first woman in the family to have a post-secondary education. She is now studying medicine at University.
[25] M. AlMunajjed, *Women in Saudi Arabia Today* (New York: St. Martin's Press,1997), p.47.
[26] *New Statesman*, 27 March 1992, cover page.
[27] *The Atlanta Journal/The Atlanta Constitution*, June 28, 1992, Section P.
[28] *L'Express*, (Quebec), November 17, 1994, cover page.
[29] *Le Nouvel Observateur*, September 28, 1994.
[30] *Toronto Star*, May 14, 1996, F5.
[31] *Vancouver Sun*, September 15, 1994, A18.
[32] *Montreal Gazette*, April 11, 1994, B3.
[33] *Toronto Star*, December 15, 1996, F4.
[34] Deborah Scroggins, "Women of the Veil: Islamic Militants Pushing Women Back to an Age of Official Servitude," *The Atlanta Journal/The Atlanta Constitution*, Sunday, June 28, 1992, p.P3.
[35] Jan Goodwin, *Price of Honor: Muslim Women Lift the Veil of Silence on the Islamic World*, (New York: Plume, 1994), p.262.
[36] Ibid., pp.55, 78–9, 81, 98, 101, 107–9, 293, 300; Scroggins, "Women of the Veil," p.P3
[37] Goodwin, *Price of Honor*, pp.112, 161, 186–7, 217, 247, 342. Goodwin presents some women who cover as not fundamentalists and fearing fundamentalism, p.85; Scroggins, "Women of the Veil," p.P2. Geraldine Brooks, *Nine Parts of Desire: The Hidden World of Islamic Women*, (N.Y.: Doubleday, 1995), p.8.
[38] Goodwin, *Price of Honor*, pp.137, 175.
[39] Andrea B. Rugh, *Reveal and Conceal: Dress in Contemporary Egypt* (Syracuse, New York: Syracuse University Press, 1986).
[40] S. Brenner, "Reconstructing Self and Society: Javanese Muslim Women and the Veil," *American Ethnologist*, 23, 4, (1996).
[41] Fatima Mernissi, *Beyond the Veil: Male-Female Dynamics in Modern Muslim Society* (Revised ed, Indiana: Indiana University Press, 1987), and *The Veil and the Male Elite: A Feminist Interpretation of Women's Rights in Islam*, Trans. Mary Jo Lakeland (Reading, Massachusetts: Addison-Wesley Publishing Co., 1991).

[42] Fatima Mernissi, *Dreams of Trespass: Tales of a Harem Girlhood* (Reading, Massachusetts: Addison-Wesley Publishing Co., 1994), p.100.
[43] Ibid.
[44] Mernissi, *Beyond the Veil,* p.82.
[45] Ibid.
[46] T.J. Winter, "Desire and Decency in the Islamic Tradition," *Islamica* (United Kingdom), 1, 4, (January 1994), pp.11–12.
[47] Mernissi, *Beyond the Veil*, p.107.
[48] Naheed Mustapha, "My Body is my Own Business," *Globe and Mail,* Facts and Arguments, Tuesday, June 29, 1993; Yusufali: "My Body is My Own Business," *The Toronto Star*, Tuesday, February 17,1998, C:1.
[49] Susie Orbach, *Fat is a Feminist Issue: A Self-Help Guide for Compulsive Eaters* (New York: Berkeley Books, 1979); Susan Bordo, *Unbearable Weight: Feminism, Western Culture, and the Body* (Berkeley, Calif.: University of California Press, 1993); Naomi Wolf, *The Beauty Myth: How Images of Beauty are Used Against Women* (1991, 2nd Ed, New York: Anchor, 1992); Jane Ussher, *Fantasies of Femininity: Reframing the Boundaries of Sex* (London: Penguin, 1997); Catherine A. MacKinnon, "Sexuality, Pornography, and Method: Pleasure Under Patriarchy," in *Feminism and Philosophy: Essential Readings in Theory, Reinterpretation, and Application*, eds. Nancy Tuana and Rosemarie Tong (Boulder: Westview Press, 1995); A. Dworkin, "Pornography is a Civil Rights Issue," in *Debating Sexual Correctness: Pornography, Sexual Harassment, Date Rape, and the Politics of Sexual Equality*, ed. Adele M. Stan (New York: Delta, 1995).
[50] John Berger, Sven Blomberg, Chris Fox, Michael Dibb and Richard Hollis, *Ways of Seeing* (London: BBC and Penguin, 1972).
[51] MacKinnon, "Sexuality, Pornography, and Method," p.142.
[52] Michael F. Jacobson and Laurie Ann Mazur, *Marketing Madness: A Survival Guide for a Consumer Society* (Boulder: Westview Press, 1995), pp.84–5.
[53] Bordo, *Unbearable Weight*, p.290. Also pp.246–7, 275.

IIIT Books-In-Brief Series គឺជាការប្រមូលដ៏មានតម្លៃនៃការបោះពុម្ពផ្សាយសំខាន់ៗរបស់វិទ្យាស្ថានទស្សនៈអ៊ីស្លាមអន្តរជាតិ រៀបរៀងជាទម្រង់បង្រួម ផ្តល់ឱ្យអ្នកអាននូវការយល់ដឹងអំពីខ្លឹមសារសំខាន់ៗនៃសៀវភៅច្បាប់ដើម។

តម្រូវការដើម្បីប្រឈមនឹងគំរូអវិជ្ជមាន អំពីការលើកឡើងថា ហ៊ីហ្សាប ឬស្បៃគ្របមុខ គឺជាការគៀបសង្កត់គឺស្ថិតក្នុងភាពបន្ទាន់។ វាមាននៅក្នុងគំនិតរបស់មនុស្សជាច្រើននិងមានការជជែកពិភាក្សាថាតើត្រូវទទួល ឬមិនត្រូវទទួលហ៊ីហ្សាបគឺកាន់តែក្តៅឡើង នៅតាមប្រព័ន្ធផ្សព្វផ្សាយ ពោលការលាបពណ៌លើហ៊ីហ្សាបគឺស្មើនឹងន័យថាវាជាការដើរថយក្រោយរបស់អ្នកមូស្លីម និងជាភាពភាពព្រៃផ្សៃរបស់អ៊ីស្លាម។ ស្នាដៃនេះផ្តោតលើទិដ្ឋភាពវប្បធម៌លោកខាងលិចដ៏ពេញនិយមដែលចោទប្រកាន់ថាស្បៃមុខឬហ៊ីហ្សាប វាគឺជាការគៀបសង្កត់សម្រាប់ស្ត្រីមូស្លីម និងគូសបញ្ជាក់គំរូមូលដ្ឋាននៃអំណាចនៅពីក្រោយរូបភាពស្បៃគ្របមុខ ឬហ៊ីហ្សាបនេះ។ ពិនិត្យឫសគល់របស់វាគឺចេញពីអាណានិគមលោកខាងលិចពីគំរូអវិជ្ជមាននេះ និងវាត្រូវបានធ្វើដោយជោគជ័យក្នុងការប្រឈមមុខនឹងទឡ្ហីករណ៍របស់ពួកអ្នកស្ត្រីនិយម ពួកសេរីនិយមដូចជា Mernissi ដែលបានអះអាងថាពីវប្បធម៌នៃស្បៃមុខ ឬហ៊ីហ្សាបដែលលើកឡើងពោលក្នុងន័យថាការទទួលហ៊ីហ្សាបគឺជាការដកខ្លួនចេញពីភាពស្រស់ស្អាតនិង"ឧត្តមគតិ"ឬភាពចង់បានរបស់ស្ត្រី។

**Shaykh Hamza Yusuf Hanson ស្ថាបនិក និងប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានហ្សៃតូណា**

ស្បៃមុខ ឬហ៊ីហ្សាបគឺជាចំណុចមួយនៅក្នុងសេចក្តីបង្រៀនរបស់អ៊ីស្លាមបច្ចុប្បន្ន។ អត្ថបទគួរឱ្យចាប់អារម្មណ៍ជាច្រើនត្រូវបានសរសេររៀបរៀងឡើង ប៉ុន្តែវាតិចដែលជាស្នាដៃមកពីខាងស្ត្រី។ សៀវភៅនេះត្រូវតែអានសម្រាប់អ្នកដែលចូលរួមក្នុងក្នុងទស្សនទាននៃទិដ្ឋភាពសង្គមមូស្លីមបច្ចុប្បន្ន ទាំងនៅលោកខាងកើត ឬលោកខាងលិច។ សៀវភៅរបស់លោកបណ្ឌិត Bullock សមនឹងទទួលនការយកចិត្តទុកដាក់ខ្លាំងបំផុត ព្រោះវាប្រឈមមុខនៃចំណោទបញ្ហាទៅនឹងការសន្មត់អាក្រក់គិតទុករួចជាស្រេចដែលចាក់ឫសយ៉ាងជ្រៅបំផុតដែលយើងឃើញមាននៅលោកខាងលិចមានអំពីស្បៃគ្របមុខ ឬហ៊ីហ្សាប និងអត្ថន័យខ្លឹមសាររបស់វា។

**Julian Bond នាយកវេទិកាគ្រីស្ទាននិងមូស្លីម**

នេះគឺជាសៀវភៅសង្ខេបមានរយៈពេលខ្លីជាងសៀវភៅដែលបានបោះពុម្ពផ្សាយលើកដំបូង។ ទស្សនៈរបស់អ្នកនិពន្ធគឺអំពីស្ត្រី 'លោកខាងលិច' ដែលមានការយល់ច្រឡំអំពី 'ស្បៃមុខ ឬហ៊ីហ្សាប' ដែលបន្ទាប់មកពោលអ្នកនិពន្ធសៀវភៅនេះបានចាប់ផ្តើមទទួលហ៊ីហ្សាប នៅពេលដែលលោកស្រីបានផ្លាស់ប្តូរក្លាយជាអ្នកមូស្លីម។ វាជាអំណាយដ៏ស្រស់ស្រាយ សរសេរបានល្អ ប្រកបដោយភាពស្មោះត្រង់ និងគួរឱ្យចាប់អារម្មណ៍។ មិនមានការយកចិត្តទុកដាក់ឬផ្តោតខ្លាំងពេកលើបញ្ហា អ្នកនិពន្ធពិតជាបានស្តាប់បទពិសោធន៍របស់ស្ត្រីមូស្លីមអំពីការទទួលហ៊ីហ្សាប និងអនុញ្ញាតឱ្យពួកគេនិយាយតាមសំដីពោលការយល់ឃើញរបស់ពួកគេផ្ទាល់។ ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងផ្តល់ជូននូវព័ត៌មាន ការស្វែងយល់ដល់មិត្តអ្នកអានថ្មីៗដើម្បីឱ្យពួកគេឆ្លុះបញ្ចាំងសម្រាប់ខ្លួនគេលើបញ្ហានេះ។

979-8-89193-400-9

9 798891 934009

Cambodia Office
IIIT Books-in-Brief